# សេចក្តីព្រាងក្របខ័ណ្ឌត្រួតពិនិត្យ ការវាយតម្លៃបរិស្ថាន

ខែកញ្ញា ឆ្នាំ២០២២

## 53240-003៖ គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែច្រវាក់តម្លៃសត្វ (ប្រទេសកម្ពុជា)



FCG. Aets apave SYNERGIA Consulting & Training TANCONS Community & Environmental Services Ltd

រៀបចំដោយក្រុមហ៊ុន FCG ANZDEC Ltd (FCG នៃប្រទេសនូវែលសេឡង់) ក្នុងការបណ្តាក់ទុនរួមគ្នាជាមួយក្រុមហ៊ុន Finnish Consulting Group Asia (FCG នៃប្រទេសសិង្ហបុរី) និងសហការជាមួយ AETS, Synergia, TANCONS, ក្រុមហ៊ុន CES Ltd នៃរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# មាតិកា


I. **សេចក្តីផ្តើម** ........ 4

ក. ការវិនិយោគ និងអនុគម្រោងសំខាន់ៗ សម្រាប់ការផ្តល់មូលនិធិគម្រោង ........ 4

ខ. គោលបំណងនៃក្របខ័ណ្ឌបរិស្ថាន ........ 5

II. **ក្របខ័ណ្ឌច្បាប់ និងសមត្ថភាពស្ថាប័ននៅប្រទេសកម្ពុជា** ........ 6

ក. ក្របខ័ណ្ឌច្បាប់កម្ពុជាសម្រាប់បរិស្ថាន ........ 6

ខ. លក្ខខណ្ឌតម្រូវផ្នែកការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ........ 8

III. **ផលប៉ះពាល់បរិស្ថានដែលមានសក្តានុពល** ........ 10

IV. **ដំណើរការពិនិត្យ និងជ្រើសរើសអនុគម្រោង** ........ 11

ក. នីតិវិធីពិនិត្យបរិស្ថាន ........ 11

ខ. ការវាយតម្លៃបរិស្ថាន និងការពិនិត្យឡើងវិញលើអនុគម្រោង ........ 13

V. **ការអនុវត្ត និងការពិនិត្យតាមដាន** ........ 15

ក. ការទទួលខុសត្រូវ និងការរៀបចំស្ថាប័ន ........ 15

ខ. លក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យ និងការរាយការណ៍ ........ 16

គ. ការប្រែប្រួលនៃអនុគម្រោង និងការមិនអនុលោមតាម ........ 16

ឃ. ការពិគ្រោះយោបល់ជាសាធារណៈ និងការបញ្ចេញព័ត៌មាន ........ 17

ង. យន្តការបណ្តឹងសាទុក្ខ (បណ្តឹងតវ៉ា) ........ 18

**ឧបសម្ព័ន្ធ** A. **ការពិនិត្យដើម្បីចាត់ចំណាត់ថ្នាក់ប្រភេទបរិស្ថាន** ........ 20

**ឧបសម្ព័ន្ធ** B. **បញ្ជីសកម្មភាពវិនិយោគដែលត្រូវហាមឃាត់របស់** ADB ........ 23

**ឧបសម្ព័ន្ធ** C. **ក្រមបរិស្ថាននៃការអនុវត្តសម្រាប់ការសាងសង់** ........ 25

**ឧបសម្ព័ន្ធ** D. **ក្រមបរិស្ថាននៃការអនុវត្តសម្រាប់ប្រតិបត្តិការផ្សារត្រីស្រស់**[sic] ........ 36

**ឧបសម្ព័ន្ធ** E. **ការគ្រប់គ្រងហានិភ័យនៃជំងឺកូវីដ-១៩** (COVID-19) ........ 38


## បញ្ជីតារាង


**តារាងទី** 1. លក្ខណៈវិនិច្ឆ័យនៃការចាត់ចំណាត់ថ្នាក់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួមផ្សំសម្រាប់គម្រោង CLHVCIP ........ 7




INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AHP | សុខភាពសត្វ និងផលិតកម្មសត្វ |
| AI | ការបង្កាត់ពូជសិប្បនិម្មិត |
| BSC | ទូកញ្ចក់ជីវសុវត្ថិភាព |
| CAM | កម្ពុជា ឬប្រទេសកម្ពុជា |
| CLHVCIP | គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែប្រវាក់តម្លៃសត្វ |
| CSE | វិស្វករត្រួតពិនិត្យការសាងសង់ |
| EA | ភ្នាក់ងារប្រតិបត្តិ |
| EARF | ក្របខ័ណ្ឌវាយតម្លៃ និងត្រួតពិនិត្យបរិស្ថាន |
| EHS | បរិស្ថាន សុខភាព និងសុវត្ថិភាព |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| GDAHP | អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| GMP | ការអនុវត្តផលិតកម្មល្អ |
| GRM | យន្តការដោះស្រាយបណ្តឹងសាទុក្ខ (ឬបណ្តឹងតវ៉ា) |
| HACCP | ការវិភាគលើគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ |
| HEPF | តម្រងខ្យល់ភាគល្អិតដែលមានប្រសិទ្ធភាពខ្ពស់ |
| IBAT | ឧបករណ៍វាយតម្លៃជីវចម្រុះរួម |
| IEE | ការត្រួតពិនិត្យបរិស្ថានបឋម |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IUCN | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |
| MoE | ក្រសួងបរិស្ថាន |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NCBC | មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ |
| NAHPRI | វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ |
| NPMO | ការិយាល័យជាតិគ្រប់គ្រងគម្រោង |
| OM | ឧត្តរមានជ័យ |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| PIMC | ទីប្រឹក្សាគ្រប់គ្រងការអនុវត្តគម្រោង |
| PPIU | អង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត |
| POAHP | ការិយាល័យផលិតកម្ម និងបសុព្យាបាល |
| PPN | ភ្នំពេញ |
| PPUC | អង្គភាពទទួលបណ្តឹងសាធារណៈនៃគម្រោង |
| QC | មណ្ឌលចត្តាឡីស័ក |
| SOP | នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា |
| TSA | អាជ្ញាធរទន្លេសាប |
| TSBR | ឋបនីជីវមណ្ឌលបឹងទន្លេសាប |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ |
| VDL | មន្ទីរពិសោធន៍ពេទ្យសត្វ |
| VOC | សមាសធាតុសរីរាង្គងាយបង្កជាហេតុ |
| VPC | មជ្ឈមណ្ឌលផលិតវ៉ាក់សាំង |
| WB | ធនាគារពិភពលោក |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# I. សេចក្តីផ្តើម

១. គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែច្រវាក់តម្លៃសត្វ (GSM-CLHVCIP) គឺជាអាទិភាពមួយក្នុងយុទ្ធសាស្ត្រលើកកម្ពស់ខ្សែច្រវាក់តម្លៃផ្អែកលើកសិផល ប្រកបដោយសុវត្ថិភាព និងមានលក្ខណៈមេត្រីភាពចំពោះបរិស្ថាននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលបានអនុម័តដោយរដ្ឋមន្ត្រីកសិកម្មនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ កាលពីខែកញ្ញា ឆ្នាំ២០១៧ រួមទាំងប្រទេសកម្ពុជាផងដែរ។ គោលគំនិតសំខាន់នៃគម្រោងនេះ ត្រូវបានបង្កើតឡើងតាមរយៈការពិគ្រោះយោបល់នៅក្នុងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ រួមទាំងប្រទេសកម្ពុជា កាលពីចន្លោះខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០១៩។

## ក. ការវិនិយោគ និងអនុគម្រោងសំខាន់ៗ សម្រាប់ការផ្តល់មូលនិធិគម្រោង

២. គម្រោងដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជានេះ មានលក្ខណៈស្របតាមផលជះ៖ ចក្ខុវិស័យនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ គឺត្រូវតែសម្រេចឱ្យបាននូវតួនាទីជាអ្នកផ្គត់ផ្គង់ឈានមុខគេលើផលិតផលកសិកម្មប្រកបដោយសុវត្ថិភាព និងមានលក្ខណៈមេត្រីភាពចំពោះបរិស្ថាន។ លទ្ធផលនៃគម្រោងនេះ គឺការកែលម្អសុខភាព ខ្សែច្រវាក់តម្លៃ និងពាណិជ្ជកម្មផ្លូវការនៃបសុសត្វ និងផលិតផលបសុសត្វ។ គម្រោងនេះ មានលទ្ធផលចំនួនបី ដូចខាងក្រោម៖

**លទ្ធផលទី ១៖** ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វ និងខ្សែច្រវាក់តម្លៃសត្វ ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ។ សកម្មភាពសំខាន់ៗត្រូវបានដាក់ជាក្រុម៖ (១) មណ្ឌលចត្តាឡីស័ក និងតំបន់ត្រួតពិនិត្យជំងឺ; (២) មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ; (៣) មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ; (៤) ផ្សារលក់មាន់ទារស់ដូនកែវ; (៥) វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ; (៦) ទីសត្តឃាតសាធារណៈ និងផ្សារក្រមួន; និង (៧) ហេដ្ឋារចនាសម្ព័ន្ធសម្របទៅនឹងការប្រែប្រួលអាកាសធាតុ។

**លទ្ធផលទី ២៖** សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលបសុសត្វ ត្រូវបានពង្រឹង។ គំនិតផ្តួចផ្តើមសំខាន់ៗនៅក្រោមលទ្ធផលនេះ រួមមានការផ្តល់នូវ៖ (១). ការកែលម្អសុខភាពសត្វតាមរយៈកម្មវិធីបង្ការរោគរាតត្បាតលើសត្វពាហនៈ និងព័ត៌មានវិទ្យា; (២). សេវាអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃសត្វ តាមរយៈការណែនាំអំពីការអនុវត្តល្អលើការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យសាច់សត្វដោយផ្អែកលើហានិភ័យ; (៣). សេវាកម្មផលិតកម្មសត្វ រួមទាំងការអនុវត្តល្អលើការចិញ្ចឹមសត្វពាហនៈ និផលិតកម្មចំណីសត្វ; (៤). ការកសាងសមត្ថភាព; និង (៥). ការបន្សាំបច្ចេកវិទ្យាទៅនឹងការប្រែប្រួលអាកាសធាតុ។

**លទ្ធផលទី ៣៖** ការរៀបចំគោលនយោបាយសម្រាប់ការផ្គត់ផ្គង់កាន់តែប្រសើរឡើង សុខភាព សុវត្ថិភាព និងពាណិជ្ជកម្ម និងផលិតផលសត្វ ត្រូវបានធ្វើឱ្យប្រសើរឡើង។ គម្រោងនេះនឹងគាំទ្រដល់សកម្មភាពគោលនយោបាយចំនួន ៥ ក្រុម៖ (១). គោលនយោបាយជាតិស្តីពីបសុសត្វ (២). គោលនយោបាយស្តី



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

ពីពាណិជ្ជកម្មសត្វឆ្លងកាត់ព្រំដែន។ (៣). បទប្បញ្ញត្តិ និងស្តង់ដា; (៤). ការអភិវឌ្ឍន៍វិស័យបសុសត្វឯកជន និង (៥). គោលនយោបាយស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## ខ. គោលបំណងនៃក្របខ័ណ្ឌបរិស្ថាន

៣. ក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) កំណត់លក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការពិនិត្យ (ការចាត់ថ្នាក់) ការវាយតម្លៃ និងការគ្រប់គ្រងហេតុប៉ះពាល់បរិស្ថាននៃសកម្មភាពគម្រោង និងអនុគម្រោងទាំងអស់ ដែលនឹងត្រូវបានកំណត់អត្តសញ្ញាណនៅពេលក្រោយនៃការអនុវត្តគម្រោង (ពោលគឺ បន្ទាប់ពីទទួលបានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍អាស៊ី ADB) ដើម្បីធានាបាននូវការអនុលោមតាមលក្ខខណ្ឌតម្រូវនៃការពារបរិស្ថានរបស់ប្រទេសកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី។ ក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) ចងក្រងជាឯកសារនូវដំណើរការអនុវត្តការតព្វកិច្ចផ្នែកគោលនយោបាយបរិស្ថានខាងលើ ដែលត្រូវតែអនុវត្តសម្រាប់អនុគម្រោងតំណាង ផលប៉ះពាល់អវិជ្ជមានដែលបានរំពឹងទុក និងវិធានការកាត់បន្ថយ ក៏ដូចជាការរៀបចំការអនុវត្តដែលបានស្នើឡើង។ ក្របខ័ណ្ឌនេះ គឺជាបទប្បញ្ញត្តិបរិស្ថានដែលអាចអនុវត្តបានទាំងនៅក្នុងប្រទេស និងអន្តរជាតិ រួមទាំងលក្ខខណ្ឌតម្រូវនៃសេចក្តីថ្លែងគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ អនុគម្រោងដែលត្រូវបានរៀបចំរួចហើយនេះគួរតែអនុវត្តស្របតាមការណែនាំទូទៅដែលមាននៅក្នុងក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) និងវិធានការកាត់បន្ថយផលប៉ះពាល់ជាក់លាក់នៃអនុគម្រោង ដែលមានចែងនៅក្នុងឧបករណ៍កិច្ចគាំពារបរិស្ថានដទៃទៀត ក៏ដូចជាការត្រួតពិនិត្យបរិស្ថានបឋម (IEE) និងផែនការគ្រប់គ្រងបរិស្ថាន (EMP)។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

## II. ក្របខ័ណ្ឌច្បាប់ និងសមត្ថភាពស្ថាប័ននៅប្រទេសកម្ពុជា

៤. ការរចនា ការសាងសង់ និងប្រតិបត្តិការនៃអនុគម្រោងទាំងអស់ ត្រូវតែអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាបរិស្ថាន ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា និងលក្ខខណ្ឌតម្រូវនៃគោលនយោបាយកិច្ចគាំពារសង្គម និងបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

### ក. ក្របខ័ណ្ឌច្បាប់កម្ពុជាសម្រាប់បរិស្ថាន

៥. ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (នស/រកម/១២៩៦/៣៦) ដែលអនុម័តដោយរដ្ឋសភាជាតិ ក្នុងឆ្នាំ១៩៩៦ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម (នស/រកម-១២៩៦/៣៦) គឺជាច្បាប់គោលសម្រាប់ការគ្រប់គ្រងបរិស្ថាន។ ការទទួលខុសត្រូវ និងនីតិវិធីសម្រាប់អនុវត្តការវាយតម្លៃបរិស្ថាន រួមនឹងលក្ខខណ្ឌតម្រូវសម្រាប់ការត្រួតពិនិត្យបរិស្ថាននៃគម្រោងនានា ត្រូវបានបញ្ជាក់លម្អិតនៅក្នុងអនុក្រឹត្យលេខ ៧២ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

៦. ដើម្បីផ្តល់ជាការណែនាំអំពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ ក្រសួងបរិស្ថានបានប្រកាសឱ្យប្រើអនុក្រឹត្យលេខ ២១ ស្តីពីចំណាត់ថ្នាក់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍នានា។ យោងតាមអនុក្រឹត្យនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងនីមួយៗ ត្រូវបានចាត់ថ្នាក់ជាបីប្រភេទ៖

(១). គម្រោងដែលទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) ដែលសមមូលនឹងប្រភេទបរិស្ថាន A របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
(២). គម្រោងដែលទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម (IEIA) ដែលសមមូលនឹងប្រភេទបរិស្ថាន B របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
(៣). គម្រោងដែលទាមទារឱ្យមានកិច្ចសន្យាស្តីពីការការពារបរិស្ថាន (EPC) ដែលសមមូលនឹងប្រភេទបរិស្ថាន C របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បូកនឹងសាមញ្ញ ៣។

៧. ការវិភាគលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងលើផែនការគ្រប់គ្រងបរិស្ថាន (EMP)៖ គឺជាសេចក្តីដកស្រង់មួយនៃការចាត់ថ្នាក់ដោយផ្អែកលើកម្រិតនៅប្រទេសកម្ពុជា ដែលគ្របដណ្តប់លើសកម្មភាពកសិកម្មដែលទំនងជាត្រូវបានចាត់ទុកថាជាផ្នែកមួយនៃគម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែននៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែប្រវាក់តម្លៃសត្វ (CLHVCIP) ដូចមានបង្ហាញនៅក្នុងតារាងទី ១ ខាងក្រោម។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

**តារាងទី 1. លក្ខណៈវិនិច្ឆ័យនៃការចាត់ថ្នាក់**

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួមផ្សំ សម្រាប់គម្រោង CLHVCIP**

| **ប្រភេទគម្រោង និងសកម្មភាព** | **ទាមទារ ESIA** ( ADB′s cat. A ) | **ទាមទារ ESIA** ( ADB′s cat. B ) | **ទាមទារ EPC** ( EMP, equal ADB cat. C+ ) |
|---|---|---|---|
| កន្លែងសត្តឃាត | >ក្បាល/ថ្ងៃ* | ≥100 ក្បាល/ថ្ងៃ | 10 - <100 ក្បាល/ថ្ងៃ |
| កសិដ្ឋានចិញ្ចឹមសត្វ ( គោ ក្របី សេះ និង សត្វដទៃទៀត ) | <5000 ក្បាល* (or 4000?) | ≥500 ក្បាល | 100- < 500 ក្បាល |
| កសិដ្ឋានបសុបក្សី | | ≥50,000 ក្បាល | 5,000-<50,000 |
| កន្លែងកែច្នៃម្ហូបអាហារ និងអាហារកំប៉ុង | | ≥500 តោន/ឆ្នាំ | <500 តោន/ឆ្នាំ |
| កន្លែងកែសម្លស្ស និងកែច្នៃស្បែក | គ្រប់ទំហំ | | |
| កសិដ្ឋានចិញ្ចឹមមាន់ ទា និងសត្វស្លាបដទៃទៀតដែលចិញ្ចឹមសម្រាប់យកសាច់ និង/ឬពង | | ≥ 50,000 ក្បាល | 5,000 - < 50,000 ក្បាល |
| រោងចក្រផលិតចំណីសត្វ | | ≥10,000 តោន/ឆ្នាំ | <10,000 តោន/ឆ្នាំ (30 តោន/ថ្ងៃ) |
| មន្ទីរពិសោធន៍ | | គ្រប់ទំហំ | |
| កន្លែងប្រព្រឹត្តកម្មទឹកកង្វក់ពីធម្មជាតិ និងប្រព័ន្ធលូ | | គ្រប់ទំហំ | |
| រោងចក្រផលិតជីសរីរាង្គ | | គ្រប់ទំហំ | |

*កម្រិតកំណត់ដែលបានរចនាឡើងដើម្បីពិនិត្យតែទៅលើអនុគម្រោងដែលមានផលប៉ះពាល់បរិស្ថាននៅក្នុងប្រភេទ B របស់ ADB សម្រាប់វិស័យ ឬអនុវិស័យគោលដៅ ដែលទាំងអស់នេះត្រូវបានចាត់ទុកថាជាប្រភេទ B ឬ C ក្នុងប្រទេស ប៉ុន្តែមិនយល់ស្របពី ADB ទេ។ ដូច្នេះ លក្ខណៈវិនិច្ឆ័យ EIA របស់គម្រោង ត្រូវរួមបញ្ចូលទាំងការពិចារណាក្នុងប្រទេស និង ADB។

៨. អនុលោមតាមអនុក្រឹត្យពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ( EIA ) អ្នកស្នើគម្រោងត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថាន និងការអនុវត្តតាមលក្ខខណ្ឌតម្រូវដែលបានព្រមព្រៀងចំពោះគម្រោងដែលបានកំណត់ រួមទាំងវិធានការកាត់បន្ថយ និងការត្រួតពិនិត្យ។ ក្រសួងបរិស្ថាន ត្រូវទទួលខុសត្រូវលើការត្រួតពិនិត្យ និងអនុម័តរបាយការណ៍វាយតម្លៃបរិស្ថាន ការចេញវិញ្ញាបនបត្របញ្ជាក់អនុលោមភាពបរិស្ថាន ( ឧ. ការអនុម័តរបាយការណ៍វាយតម្លៃបរិស្ថាន ) និងការត្រួតពិនិត្យផែនការគ្រប់គ្រងបរិស្ថាន ( EMP ) ដែលសំដៅផងដែរថាជាផែនការគ្រប់គ្រង ត្រួតពិនិត្យបរិស្ថាន និងអនុវត្តបរិស្ថាន។ មុខងារទាំងនេះអាចត្រូវបានបំពេញនៅថ្នាក់កណ្តាល ឬថ្នាក់ខេត្ត អាស្រ័យលើវិសាលភាព ទំហំ និងលក្ខណៈនៃអនុគម្រោង។ ជាទូទៅ ការិយាល័យគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានខេត្ត ( PONRE ) គឺជាអង្គភាពទទួលខុសត្រូវចំពោះការត្រួតពិនិត្យលើប្រភេទគម្រោងដែលទាមទារឱ្យមានការត្រួតពិនិត្យបរិស្ថានបឋម ( IEE )។

៩. កម្រិតស្តង់ដាដែលអនុវត្តចំពោះការបញ្ចេញ ការបំភាយ និងការបំពុល ត្រូវបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ( ឆ្នាំ១៩៩៩ ), អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ( ឆ្នាំ១៩៩៩ ), អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលទឹក ( ឆ្នាំ២០០៩ ), អនុក្រឹត្យស្តីពីការគ្រប់គ្រង



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

ការបំពុលបរិយាកាស និងការរំខានដោយសំឡេង (ឆ្នាំ២០០០), និងអនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់ ចេញដោយនាយករដ្ឋមន្ត្រី ឆ្នាំ២០១៧។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថាស្តង់ដាជាតិ និងគោលការណ៍ណែនាំអន្តរជាតិត្រូវបានអនុវត្តកាន់តែតឹងរ៉ឹងសម្រាប់គម្រោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ជាពិសេស សេចក្តីថ្លែងគោលនយោបាយការពាររបស់ធនាគារ ADB (SPS 2009) តម្រូវឱ្យគម្រោងនានាចាំបាច់អនុវត្តបច្ចេកវិទ្យា និងការគ្រប់គ្រងការបំពុលបរិស្ថាន និងការអនុវត្តស្របតាមការអនុវត្តល្អជាអន្តរជាតិ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងស្តង់ដាដែលទទួលស្គាល់ជាអន្តរជាតិ ដូចជាគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព (EHS) របស់ក្រុមធនាគារពិភពលោក ដែលជារឿយៗត្រូវបានសំដៅថាជាគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកមួយនៃក្រុមធនាគារពិភពលោក។ គោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព (EHS) សំដៅលើគោលការណ៍ណែនាំទឹកស្អាតរបស់អង្គការសុខភាពពិភពលោក និងការអនុវត្តឧស្សាហកម្មល្អដទៃទៀតនៅទូទាំងពិភពលោក។ គោលការណ៍ណែនាំ EHS ផ្តោតសំខាន់លើការបញ្ចេញទឹកកង្វក់ និងការបំភាយ និងលើការបញ្ចៀសការរេចរឹលនៃប្រភពទឹកសម្រាប់បរិភោគ។ គោលការណ៍ណែនាំនេះ មិនគ្របដណ្តប់លើគុណភាពទឹក និងខ្យល់បរិយាកាសនោះទេ ហើយដូច្នេះស្តង់ដាជាតិសម្រាប់ការព្យាករណ៍អាយុជីវិតក្នុងទឹក និងសុខភាពមនុស្ស ត្រូវបានអនុវត្ត។

១០. នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន មានតួនាទីត្រួតពិនិត្យ និងគ្រប់គ្រងលើការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងសម្របសម្រួលការអនុវត្តគម្រោង ដោយសហការជាមួយភ្នាក់ងារប្រតិបត្តិគម្រោង (EA) និងក្រសួងពាក់ព័ន្ធដទៃទៀត។ នាយកដ្ឋាន ឬការិយាល័យគាំពារបរិស្ថាន និងសង្គមរបស់ក្រសួង/មន្ទីរបរិស្ថាន បានទទួលអត្ថប្រយោជន៍លើការពង្រឹងស្ថាប័ន និងការអភិវឌ្ឍន៍សមត្ថភាពពីគម្រោងនានាដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងនេះក្តី ការអនុវត្តគោលការណ៍ការពារបរិស្ថាន និងសង្គមនៅតែមានកម្រិតមធ្យមប៉ុណ្ណោះ ដែលជាផលវិបាកនៃកង្វះបុគ្គលិកដែលបានទទួលបានការបណ្តុះបណ្តាល និងជំនាញតិចតួចពេក កង្វះទិន្នន័យបរិស្ថាន កង្វះការតាមដាន និងការត្រួតពិនិត្យលើការអនុវត្ត និងការអនុវត្តច្បាប់នៅមានកម្រិត។ ការបញ្ចេញព័ត៌មាន គឺនៅមិនទាន់ទទួលបានការពេញចិត្តនៅឡើយទេ ដោយសាររបាយការណ៍វាយតម្លៃជាទូទៅមិនត្រូវបានដាក់បង្ហាញជាសាធារណៈ ឬអាចចូលមើលបាននៅលើគេហទំព័ររបស់ក្រសួង។ លើសពីនេះ នីតិវិធីពិនិត្យ និងអនុម័តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) អាចមានសភាពស្រពេចស្រពិល ដោយគម្រោងមួយចំនួនមិនស្ថិតនៅក្រោមការវាយតម្លៃស្របតាមបទប្បញ្ញត្តិ ហើយម្យ៉ាងទៀតការវាយតម្លៃគម្រោងអាចគ្មានគុណភាពតាមការពេញចិត្តទៀតផង។

## ខ. លក្ខខណ្ឌតម្រូវផ្នែកការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

១១. លក្ខខណ្ឌតម្រូវនៃការវាយតម្លៃបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ត្រូវបានកំណត់នៅក្នុងសេចក្តីថ្លែងគោលនយោបាយការពារ (ADB-SPS) សេចក្តីណែនាំ និងកំណត់ចំណាំគោលការណ៍ណែនាំ។ គោលបំណងសំខាន់នៃការការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គឺដើម្បីៈ បញ្ចៀសផលប៉ះពាល់អវិជ្ជមាននៃគម្រោងទៅលើបរិស្ថាន និងប្រជាជនដែលរងផលប៉ះពាល់ តាមដែលអាចធ្វើទៅបាន, សម្រាលឱ្យ



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

នៅតិចតួច កាត់បន្ថយ និង/ឬទូទាត់សំណងចំពោះផលប៉ះពាល់អវិជ្ជមាននៃគម្រោងលើបរិស្ថាន និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ នៅពេលដែលមិនអាចជៀសវាងបាន។

១២. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អនុវត្តនីតិវិធីពិនិត្យ និងការចាត់ថ្នាក់នៅដំណាក់កាលដំបូងបំផុតនៃការរៀបចំអនុគម្រោង នៅពេលដែលមានព័ត៌មានគ្រប់គ្រាន់សម្រាប់គោលបំណងនេះ។ ការពិនិត្យ និងការចាត់ចំណាត់ថ្នាក់ត្រូវបានអនុវត្តដើម្បី៖ វាយតម្លៃសារៈសំខាន់នៃផលប៉ះពាល់សក្តានុពល ឬហានិភ័យដែលអាចកើតមាន ដែលអនុគម្រោងអាចបង្ហាញ កំណត់កម្រិតនៃការវាយតម្លៃ និងធនធានស្ថាប័នដែលត្រូវការសម្រាប់វិធានការការពារ និងកំណត់តម្រូវការបញ្ចេញព័ត៌មាន។ គំរូឧទាហរណ៍នៃបញ្ជីត្រួតពិនិត្យ ត្រូវបានផ្តល់ជូនក្នុងឧបសម្ព័ន្ធ A។

១៣. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រើប្រាស់ប្រព័ន្ធចាត់ចំណាត់ថ្នាក់ដើម្បីឆ្លុះបញ្ចាំងពីសារៈសំខាន់នៃផលប៉ះពាល់បរិស្ថានសក្តានុពលរបស់អនុគម្រោង។ ប្រភេទអនុគម្រោង ត្រូវបានកំណត់ដោយសមាសភាគដែលរងឥទ្ធិពលបរិស្ថានរសើបបំផុត រួមទាំងផលប៉ះពាល់ដោយផ្ទាល់ ដោយប្រយោល ដោយបន្ថែមជាបន្ត និងបង្កឡើងនៅក្នុងតំបន់ដែលទទួលរងឥទ្ធិពលនៃអនុគម្រោង។ អនុគម្រោងនីមួយៗដែលបានស្នើឡើង ត្រូវបានពិនិត្យពិច័យលើប្រភេទ ទីតាំង មាត្រដ្ឋាន និងភាពរសើប និងទំហំនៃផលប៉ះពាល់បរិស្ថានដែលអាចកើតមាន។ គម្រោងនីមួយៗ ត្រូវបានចាត់ឲ្យទៅជាប្រភេទណាមួយក្នុងចំណោមទាំង ៤ ប្រភេទ ដូចខាងក្រោម៖

(១). អនុគម្រោងដែលបានស្នើឡើងត្រូវបានចាត់ថ្នាក់ជាប្រភេទ A ប្រសិនបើវាទំនងជាមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដែលមិនអាចកែសម្រួលវិញបាន មានលក្ខណៈចម្រុះ ឬមិនធ្លាប់មានពីមុនមក។ ផលប៉ះពាល់ទាំងនេះ អាចជះឥទ្ធិពលលើសពីទីតាំងគម្រោង ឬហេដ្ឋារចនាសម្ព័ន្ធគម្រោង អាស្រ័យទៅតាមការងាររូបវន្ត។ អនុគម្រោងនេះ ទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ជាចាំបាច់។ អនុគម្រោង ប្រភេទ A មិនមានសិទ្ធិទទួលបានមូលនិធិពីគម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែននៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែប្រវាក់តម្លៃសត្វ (CLHVCIP) ឡើយ។
(២). អនុគម្រោងដែលបានស្នើឡើងត្រូវបានចាត់ថ្នាក់ជាប្រភេទ B ប្រសិនបើផលប៉ះពាល់បរិស្ថានមានទំហំតិចជាងគម្រោងប្រភេទ A។ ផលប៉ះពាល់ទាំងនេះ កើតមានជាក់លាក់តែទៅលើទីតាំងការងារគម្រោង មានផលប៉ះពាល់តិចតួច អាចកែសម្រួលវិញបាន ហើយក្នុងករណីភាគច្រើនងាយបង្កើតវិធានការកាត់បន្ថយបានស្រួលជាងអនុគម្រោងប្រភេទ A។ អនុគម្រោងនេះ ទាមទារឱ្យមានការត្រួតពិនិត្យបរិស្ថានបឋម (IEE) ជាចាំបាច់។
(៣). អនុគម្រោងដែលបានស្នើឡើងត្រូវបានចាត់ថ្នាក់ជាប្រភេទ C ប្រសិនបើវាទំនងជាមានផលប៉ះពាល់បរិស្ថានតិចតួច ឬមិនមានផលប៉ះពាល់អវិជ្ជមានសោះតែម្តង។ អនុគម្រោងនេះ មិនទាមទារឱ្យមានការវាយតម្លៃផ្នែកបរិស្ថាននោះទេ ទោះបីជាមានការតម្រូវជាចាំបាច់ឱ្យពិនិត្យសារជាថ្មីឡើងវិញចំពោះអ្វីដែលបានកើតឡើងពាក់ព័ន្ធនឹងបរិស្ថានក៏ដោយ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

## III. ផលប៉ះពាល់បរិស្ថានដែលមានសក្តានុពល

១៤. ផលប៉ះពាល់បរិស្ថានដែលមានសក្តានុពលនៃអនុគម្រោង នឹងប្រែប្រួលទៅតាមប្រភេទនៃអនុគម្រោងនោះ។ ដោយគិតពីលក្ខណៈនៃអនុគម្រោងតំណាង នោះគឺការបង្កាត់ពូជសត្វ ការចិញ្ចឹមសត្វទុកដាក់សត្វសម្រាប់ការត្រួតពិនិត្យ និងការគ្រប់គ្រងជំងឺ ការធ្វើសត្តឃាត ការកែលម្អផ្សារក្រមួន ជាដើមនេះ គេរំពឹងថាផលប៉ះពាល់បរិស្ថានសំខាន់ៗ នឹងកើតមានពីដំណើរការប្រតិបត្តិការនៃសកម្មភាពខាងលើនេះ។ ទោះបីជាការសាងទីសត្តឃាត និងកន្លែងកែច្នៃចំណីអាហារ ផ្សារក្រមួន មណ្ឌលចត្តាឡីស័ក អាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមាន និងភាពរំខានដល់អ្នករស់នៅជិតខាងក៏ដោយ ក៏ផលប៉ះពាល់នៃដំណាក់កាលប្រតិបត្តិការនៅតែមានលក្ខណៈច្បាស់លាស់ជាង (ឧ. សំឡេង ក្លិន ការរេចរឹលនៃប្រភពទឹក ការបោលសំណល់រឹង និងរាវ)។ ការផ្តល់មូលនិធិដល់អនុគម្រោងសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវមន្ទីរពិសោធន៍រោគវិនិច្ឆ័យបសុសត្វ ដែលបានស្នើឡើង និងមជ្ឈមណ្ឌលផលិតវ៉ាក់សាំង អាចបង្កបញ្ហាបច្ចេកទេសបន្ថែមទៀតទាក់ទងនឹងការគ្រប់គ្រង និងការបោលសំណល់ដែលមានគ្រោះថ្នាក់ ដែលអាចឆ្លងជំងឺ និងដែលមានជាតិគីមីមិនបានត្រឹមត្រូវ។ គួរកត់សម្គាល់ផងដែរថា ដោយសារអនុគម្រោងមានជាប់ពាក់ព័ន្ធនឹងការរៀបចំកន្លែងសត្តឃាត និងមជ្ឈមណ្ឌលផលិតវ៉ាក់សាំង ដូច្នេះជាទូទៅត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទបរិស្ថាន B របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលតម្រូវឱ្យមានការរៀបចំការត្រួតពិនិត្យបរិស្ថានបឋម (IEE) ជាចាំបាច់។

១៥. ដើម្បីជៀសវាង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីអនុគម្រោងដែលមិនសូវមានផលប៉ះពាល់ ក្រមប្រតិបត្តិបរិស្ថាន (ECOP) ត្រូវប្រាប់បញ្ចូលនៅក្នុងក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) នេះដែលអាចអនុវត្តបានចំពោះគ្រប់អនុគម្រោងទាំងអស់ និងចំពោះអនុគម្រោងបរិស្ថានប្រភេទ C ។ លើសពីនេះវិធានការដាក់លាក់នៃអនុគម្រោង ចាំបាច់ត្រូវបង្កើតសម្រាប់អនុគម្រោងប្រភេទ B ដូចដែលបានរៀបរាប់លម្អិតនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន (EMP) ដោយផ្អែកលើការវាយតម្លៃហ្មត់ចត់លើផលប៉ះពាល់សក្តានុពលនៃអនុគម្រោងនោះ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# IV. ដំណើរការពិនិត្យ និងជ្រើសរើសអនុគម្រោង

១៦. ដំណើរការពិនិត្យ និងជ្រើសរើសអនុគម្រោងត្រូវបានបង្កើតឡើងដោយការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) និងទីប្រឹក្សាអនុវត្តគម្រោង (PIC) ក្រោមគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ក្របខ័ណ្ឌតក្កភាពមានដូចខាងក្រោម៖

(១). សំណើអនុគម្រោង ត្រូវបានវិនិច្ឆ័យជាលើកដំបូងទល់នឹងលក្ខណៈវិនិច្ឆ័យតិចតួចដែលបានព្រមព្រៀងគ្នារវាង NPMO និង ADB ទាក់ទងនឹងលក្ខណៈបច្ចេកទេស សេដ្ឋកិច្ច-ហិរញ្ញវត្ថុ បរិស្ថាន និងសង្គម [1]។

(២). អនុគម្រោងដែលត្រូវចាត់ក្នុងបញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់របស់ ADB (សូមមើលឧបសម្ព័ន្ធ ខ) និងបញ្ជីបដិសេធរបស់ NPMO នឹងមិនមានសិទ្ធិគ្រប់គ្រាន់សម្រាប់ការផ្តល់មូលនិធិគម្រោងនោះទេ។

(៣). មានតែអនុគម្រោងដែលមានសិទ្ធិប៉ុណ្ណោះដែលនឹងបន្តទៅដល់ដំណើរការសិក្សាសមិទ្ធិលទ្ធភាពផ្នែកបច្ចេកទេស-សេដ្ឋកិច្ច/ហិរញ្ញវត្ថុ និងការវាយតម្លៃហេតុប៉ះពាល់សង្គម-បរិស្ថាន លើកលែងតែអនុគម្រោងប្រភេទ C របស់ ADB ដែលមិនមានផលប៉ះពាល់តិចតួច ឬគ្មានផលប៉ះពាល់សោះ។

(៤). មានតែអនុគម្រោងដែលបំពេញទាំងលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបាន និងលទ្ធភាពដំណើរការសិក្សាសមិទ្ធិលទ្ធភាពប៉ុណ្ណោះដែលអាចត្រូវបានជ្រើសរើសសម្រាប់ការផ្តល់មូលនិធិគម្រោង។

## ក. នីតិវិធីពិនិត្យបរិស្ថាន

១៧. នៅពេលដែលអនុគម្រោងដែលបានស្នើឡើង បានបំពេញលក្ខខណ្ឌតម្រូវនៃការជ្រើសរើសដូចដែលបានរៀបរាប់ខាងលើ នោះនៅក្នុងសំណើត្រូវចាំបាច់មានការពិនិត្យលើបរិស្ថានជាក់លាក់បន្ថែមទៀត។ នីតិវិធីពិនិត្យបរិស្ថាន មានដូចខាងក្រោម៖

(១). អ្នកស្នើអនុគម្រោងទាំងអស់ ត្រូវដាក់សំណើតាមទម្រង់ដែលបានកំណត់ដោយការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO)។ ជាធម្មតាត្រូវរួមមានព័ត៌មានមូលដ្ឋានអំពីប្រភេទសកម្មភាព និងដំណើរការបច្ចេកទេសដែលពាក់ព័ន្ធ មាត្រដ្ឋាន និងទីតាំងអនុគម្រោងដែលចាំបាច់ដើម្បីធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលអាចកើតមាន (សូមមើលឧបសម្ព័ន្ធ A)។

(២). អនុគម្រោងដែលត្រូវបានចាត់ក្នុងបញ្ជីសកម្មភាពវិនិយោគហាមឃាត់របស់ ADB (សូមមើលឧបសម្ព័ន្ធ B) និងបញ្ជីបដិសេធរបស់ PMO នឹងមិនមានសិទ្ធិទទួលបានការផ្តល់មូលនិធិគម្រោងនោះទេ។

(៣). អនុគម្រោងដែលឆ្លងផុតលក្ខខណ្ឌតម្រូវជាអប្បបរមាខាងលើពីចំណុច ១-២ នឹងត្រូវបានពិនិត្យដោយប្រៀបធៀបសំណើរបស់ពួកគេជាមួយនឹងកម្រិតនៃការចាត់ថ្នាក់ការវាយតម្លៃហេតុប៉ះពាល់ប

[1] លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបានអនុលោមតាមអនុគម្រោង មានន័យថាអនុគម្រោងនោះត្រូវបានជ្រើសរើសក្នុងបញ្ជីសម្រាំងសម្រាប់ការវាយតម្លៃបន្ថែម។ សម្រាប់អនុគម្រោងប្រភេទ C របស់ ADB អនុគម្រោងដែលមានសិទ្ធិទទួលបាន អាចត្រូវបានជ្រើសរើសដោយមិនចាំបាច់មានការវាយតម្លៃបន្ថែម។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

បរិស្ថាន (EIA) របស់គម្រោង (តារាង ២-១) ដោយផ្អែកលើវិធាននៃការកម្រិត EIA របស់ប្រទេស ដែលត្រូវបានកែប្រែដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ធនាគារអាភិវឌ្ឍន៍អាស៊ី (ADB) ផងដែរ។

(៤). សម្រាប់អនុគម្រោងដែលត្រូវបានវិនិច្ឆ័យថាមានផលប៉ះពាល់បរិស្ថានតិចតួចបំផុត គឺអនុគម្រោងប្រភេទ C របស់ ADB ត្រូវបានផ្តល់សិទ្ធិ ហើយអនុគម្រោងនោះអាចត្រូវបានទទួលយកសម្រាប់ការផ្តល់មូលនិធិគម្រោងដោយមិនចាំបាច់មានការវាយតម្លៃផ្អែកបរិស្ថានបន្ថែមទៀតនោះទេ។

(៥). សម្រាប់អនុគម្រោងដែលត្រូវបានវិនិច្ឆ័យថាមានផលប៉ះពាល់បរិស្ថានកម្រិតមធ្យម គឺអនុគម្រោងប្រភេទ B របស់ ADB ត្រូវបានផ្តល់សិទ្ធិ ហើយចាំបាច់ត្រូវរៀបចំការវាយតម្លៃបរិស្ថានបឋម (IEE)។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃ ការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIU) អាចសម្រេចថាតើត្រូវទទួលយកអនុគម្រោងនេះ ឬអត់។

(៦). អនុគម្រោងដែលត្រូវបានវិនិច្ឆ័យថាមានផលប៉ះពាល់ខ្ពស់ដូចដែលបានកំណត់ដោយគោលនយោបាយរបស់ ADB ដែលឆ្លុះបញ្ចាំងនៅក្នុងតារាងទី ២-១ គឺជាអនុគម្រោងប្រភេទ A នឹងត្រូវបានប្រានចោល ឬដកចេញតែម្តង។

១៨. ការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់អនុគម្រោង គួរតែត្រូវបានពិចារណាផងដែរក្នុងអំឡុងពេលដំណើរការពិនិត្យខាងលើ។ ការកំណត់លក្ខណៈវិនិច្ឆ័យគម្រោង ត្រូវរួមមាន៖

(១). ទីតាំងគួរតែស្ថិតនៅក្រៅតំបន់ងាយទទួលរងទឹកជំនន់។

(២). ប្រសិនបើអាចធ្វើទៅបាន ទីតាំងគួរតែស្ថិតនៅក្នុងតំបន់ឧស្សាហកម្មដែលបានកំណត់។

(៣). ព្រំប្រទល់នៃអនុគម្រោងដែលបានស្នើឡើងត្រូវមានចម្ងាយយ៉ាងតិច ១០០ ម៉ែត្រពីទន្លេ ស្ទឹង បឹងបួរ ស្រះ និងអណ្តូង ដើម្បីជៀសវាងការបំពុលគុណភាពទឹក។

(៤). ជៀសវាងការជ្រើសរើសទីតាំងណាមួយនៅតំបន់ដែលចាត់ថាតំបន់ប្រភពទឹកក្រោមដី ពីព្រោះទឹកក្រោមដី គឺជាប្រភពទឹករួមដ៏ចាំបាច់សម្រាប់បរិភោគ។

(៥). ព្រំប្រទល់នៃអនុគម្រោងត្រូវតែមានចំងាយយ៉ាងតិច ១០០ ម៉ែត្រពីទីតាំងណាមួយដែលមានសារៈសំខាន់ខាងវប្បធម៌ ប្រវត្តិសាស្ត្រ ឬសាសនា។

(៦). ព្រំប្រទល់នៃអនុគម្រោងត្រូវតែមានចម្ងាយយ៉ាងតិច ៥ គីឡូម៉ែត្រពីព្រំប្រទល់ (ឬនៅខាងក្រៅតំបន់ទ្រនាប់ការពារ) នៃជម្រកជីវចម្រុះដែលងាយរងគ្រោះ ដោយផ្អែកលើការពិភាក្សាជាមួយក្រសួង និងស្ថាប័នដែលទទួលខុសត្រូវរបស់រដ្ឋាភិបាលទាក់ទងនឹងតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ តំបន់ឋបនីជីវមណ្ឌលបឹងទន្លេសាប (TSBS) ឬតំបន់អភិរក្ស នៅក្នុងតំបន់ដែលរងឥទ្ធិពលពីអនុគម្រោង។ យ៉ាងហោចណាស់ អាជ្ញាធរដែលទទួលខុសត្រូវលើការអនុវត្តច្បាប់នៅតំបន់ការពារដែលពាក់ព័ន្ធ ហើយដែលត្រូវបានការពារដោយស្របច្បាប់ក្រោមច្បាប់ជាតិ ឬអនុសញ្ញាអន្តរជាតិ គួរតែត្រូវបានពិគ្រោះ និងទទួលបានការជម្រះពីអាជ្ញាធរទាំងនេះ មុនពេលធ្វើការសម្រេចចិត្ត។

(៧). ព្រំប្រទល់នៃអនុគម្រោងត្រូវមានចម្ងាយយ៉ាងតិច ១០០ ម៉ែត្រពីតំបន់ស្រូបចូលនៃអណ្តូងទឹកក្រោមដី។

(៨). ជៀសវាងការកំណត់ទីតាំងអនុគម្រោងនៅចំចរន្តខ្យល់បក់បោកខ្លាំងដែលជះទៅដល់ការតាំងទីលំនៅណាមួយ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

(៩). ទីសត្តឃាត និងរោងចក្រកែច្នៃចំណីអាហាររបស់អនុគម្រោង មិនគួរមានទីតាំងនៅជិតសាលារៀន ព្រះវិហារ និងកន្លែងអាជីវកម្មសាធារណៈ និងពាណិជ្ជកម្មផ្សេងទៀតឡើយ។ ការកំណត់ចម្ងាយអប្បបរមា គួរអាស្រ័យលើការពិចារណាពីសំឡេងរំខាន និងការបំភាយក្លិន ដែលនឹងអាចកើតមាន។ តំបន់មួយចំនួនដែលអាចទំនងថានឹងមានការអភិវឌ្ឍវិស័យលំនៅដ្ឋាន និងសកម្មភាពពាណិជ្ជកម្មនាពេលអនាគត ក៏គួរត្រូវពិចារណាផងដែរ។

(១០). ទីតាំងអនុគម្រោងគួរតែអាចធ្វើដំណើរចេញចូលបានពីផ្លូវអចិន្ត្រៃយ៍ ដើម្បីអាចដឹកជញ្ជូនកសិផល សត្វពាហនៈ និងអាហារ ឬសាច់កែច្នៃទៅដល់ទីនោះបាន។

(១១). ការផ្គត់ផ្គង់ទឹកឱ្យគ្រប់គ្រាន់សម្រាប់ដំណើរការកែច្នៃ និងការរក្សាលក្ខខណ្ឌអនាម័យ គឺជាការចាំបាច់ ទៅតាមបរិមាណដែលអាចប្រើបាន និងដោយអនុលោមតាមស្តង់ដារចនាសមម្យេសម្រាប់គ្រឿងបរិក្ខារផ្សេងៗដែលពាក់ព័ន្ធ។ ប្រសិនបើការផ្គត់ផ្គង់ទឹកក្នុងក្រុងមិនអាចទៅរួច ដោយសារតែមិនមាន ឬដោយសារបរិមាណតម្រូវការរបស់អនុគម្រោងលើសពីការផ្គត់ផ្គង់ដែលមានស្រាប់ គេចាំត្រូវតែកំណត់រៀបចំឱ្យមានប្រភពផ្គត់ផ្គង់ទឹកដាច់ដោយឡែកមួយដើម្បីប្រើប្រាស់។

## ខ. ការវាយតម្លៃបរិស្ថាន និងការពិនិត្យឡើងវិញលើអនុគម្រោង

១៩. ការវាយតម្លៃបរិស្ថាននៃអនុគម្រោងដែលបានស្នើឡើង គួរតែត្រូវបានអនុវត្តដោយអ្នកស្នើផ្ទាល់។ សម្រាប់អនុគម្រោងសាធារណៈ ការវាយតម្លៃនេះសំដៅដល់ការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) ដែលគាំទ្រដោយអ្នកជំនាញផ្នែកបរិស្ថានដែលជាទីប្រឹក្សាអនុគម្រោង (PIC) ឬការិយាល័យកសិកម្ម និងរុក្ខាប្រមាញ់ខេត្តពាក់ព័ន្ធ, ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត (POAHP) និងអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIU) ដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យបរិស្ថានបឋម (IEE) ដែលជាធម្មតាត្រូវធ្វើឡើងដោយអ្នកជំនាញផ្នែកបរិស្ថានដែលជាទីប្រឹក្សាអនុគម្រោង (PIC) ឬតាមរយៈការជួលអ្នករៀបចំ IEE ដាច់ដោយឡែក។

២០. ចំពោះអនុគម្រោងប្រភេទ B របស់ ADB វិញ ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត (POAHP) និងអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIU) ចាំបាច់ត្រូវរៀបចំរបាយការណ៍ស្តីពីការត្រួតពិនិត្យបរិស្ថានបឋម (IEE) ស្របតាមលក្ខខណ្ឌតម្រូវ និងទម្រង់គំរូនៃ IEE/EMPs សម្រាប់អនុគម្រោងទាំង ៥ ដែលតំណាងឱ្យប្រភេទចម្បងនៃអនុគម្រោងប្រភេទ B។ ដោយមានការទទួលស្គាល់ពីដែនកំណត់នៃសមត្ថភាពក្នុងការងារវាយតម្លៃរបស់ខ្លួន ទើបដំណើរការខាងក្រោមនេះត្រូវបានអនុវត្តៈ

(១). សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងអនុគម្រោងកែច្នៃកសិផល អ្នកជំនាញផ្នែកបរិស្ថាននៃ PIC ជាធម្មតាត្រូវរៀបចំ IEE ក្នុងនាម POAHP/PPIU។

(២). សេចក្តីព្រាង IEE គួរតែត្រូវបានបង្ហាញនៅថ្នាក់ស្រុក និងធ្វើបច្ចុប្បន្នភាពដោយផ្អែកលើមតិយោបល់ដែលទទួលបាន ហើយបន្ទាប់មកដាក់បញ្ជូនទៅការិយាល័យ NPMO ដើម្បីពិនិត្យឡើងវិញ។

(៣). បន្ទាប់ពីការពិនិត្យឡើងវិញ ការិយាល័យ NPMO ត្រូវសម្រេចទទួលយក ឬត្រូវណែនាំដល់ POAHP/PPIU ដើម្បីផ្តល់ព័ត៌មានបន្ថែម ឬការកែប្រែណាមួយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្នុងនាមជាអ្នកស្នើគម្រោង នឹងបញ្ជូនរបាយការណ៍ IEE ទៅកាន់ក្រសួងបរិស្ថាន (MoE) ឬមន្ទីរបរិស្ថានខេត្តពាក់ព័ន្ធ (POE) ដើម្បីពិនិត្យឡើងវិញ និងចេញវិញ្ញាបនបត្រអនុលោម



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

ភាពបរិស្ថាន មុនពេលសម្រេចជ្រើសដោយការិយាល័យ NPMO សម្រាប់ការផ្តល់មូលនិធិគម្រោង ។

(៤). ប្រសិនបើរបាយការណ៍ IEE មួយត្រូវបានរៀបចំឡើងដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិជាតិ គេបានណែនាំថារបាយការណ៍នោះត្រូវរៀបចំតែមួយបានហើយ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវក្នុងប្រទេសផង និងរបស់ ADB ផង។

(៥). របាយការណ៍ IEE លើកដំបូងសម្រាប់ប្រភេទ B នៃអនុគម្រោងនីមួយៗ គួរតែត្រូវបានដាក់ជូន ADB ដើម្បីពិនិត្យឡើងវិញ និងបញ្ចេញជាព័ត៌មាន [2]។

២១. ដើម្បីជួយសម្រួលដល់ការវាយតម្លៃ និងការពិនិត្យឡើងវិញលើអនុគម្រោង ដោយនៅតែអាចរក្សាគុណភាពខ្លឹមសារដែលមាន គេគួរតែរៀបចំជារបាយការណ៍ IEE រួមតែមួយបានហើយសម្រាប់អនុគម្រោងជាច្រើនដែលជាប្រភេទស្រដៀងគ្នា ឬក្នុងតំបន់តែមួយដូចគ្នា (ឧ. អនុគម្រោងក្នុងខេត្តណាមួយ) នេះប្រសិនបើមានការអនុញ្ញាតសម្រាប់អនុគម្រោងដែលស្ថិតនៅក្រោមតម្រូវការវាយតម្លៃបរិស្ថានជាតិ។ លទ្ធផលនៃការពិនិត្យឡើងវិញលើ IEE/EIA ទាំងខាងក្នុង និងខាងក្រៅ (ក្នុងប្រទេស និងដោយ ADB) មានសេណារីយ៉ូ ដូចខាងក្រោម៖

(១). ត្រូវបានអនុម័តយល់ព្រមដោយការពិនិត្យទាំងអស់៖ អាចត្រូវបានជ្រើសរើសតាមទស្សនៈបរិស្ថាន។

(២). ត្រូវបានបដិសេធដោយការពិនិត្យណាមួយ៖ មិនត្រូវបានជ្រើសរើសទេ។

(៣). ការសិក្សាបន្ថែម ឬការកែលម្អដែលស្នើដោយការពិនិត្យណាមួយ៖ ក្នុងករណីនេះ អ្នកស្នើគម្រោងត្រូវធ្វើការជាមួយអ្នកជំនាញបរិស្ថានដែលជាទីប្រឹក្សាអនុវត្តគម្រោង (PIC) ដើម្បីកែប្រែ និងដាក់ស្នើការអនុម័តយល់ព្រមសារជាថ្មីឡើងវិញ។

២២. សម្រាប់អនុគម្រោងប្រភេទ C ក្រមប្រតិបត្តិបរិស្ថាន (ECOP) ត្រូវបានច្របាច់បញ្ចូលនៅក្នុងក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) នេះសម្រាប់ទាំងការសាងសង់ និងប្រតិបត្តិការនៃប្រភេទសកម្មភាពដែលមានផលប៉ះពាល់បរិស្ថានតិចតួចបំផុត (ឧបសម្ព័ន្ធ C)។ អនុគម្រោងប្រភេទ C ត្រូវតែប្រកាន់ខ្ជាប់នូវក្រមប្រតិបត្តិបរិស្ថាន (ECOP) រួមទាំងជូនភ្ជាប់ជាមួយនូវឯកសារដេញថ្លៃ និងកិច្ចសន្យាសាងសង់ផងដែរ។

២៣. ហានិភ័យនៃការប្រែប្រួលអាកាសធាតុ៖ ការវាយតម្លៃជារួមលើហានិភ័យអាកាសធាតុ ត្រូវបានអនុវត្តអំឡុងពេលរៀបចំរចនាគម្រោង និងអនុសាសន៍ដែលបានស្នើឡើង។ របាយការណ៍ត្រួតពិនិត្យបរិស្ថានបឋម (IEE) ជាពិសេសផែនការគ្រប់គ្រងបរិស្ថាន (EMP) របស់អនុគម្រោង ចាំបាច់ត្រូវតែគិតគូរទៅលើលទ្ធផលនៃការវាយតម្លៃ និងអនុសាសន៍នានាដែលបានស្នើឡើង។

---

[2] គោលការណ៍បរិស្ថានចំណុចទី ៦ នៃសេចក្តីថ្លែងគោលនយោបាយការពារ (SPS) បានចែងថា "តម្រូវឱ្យបញ្ចេញ ឬបង្ហាញព័ត៌មានអំពីសេចក្តីព្រាងការវាយតម្លៃបរិស្ថាន (រួមទាំងផែនការគ្រប់គ្រងបរិស្ថាន EMP) ឱ្យបានទាន់ពេលវេលា មុនពេលវាយតម្លៃគម្រោង ផ្តល់ឱ្យនៅនឹងកន្លែង និងជាទម្រង់ និងភាសាដែលអាចយល់បានចំពោះក្រុមអ្នករងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត" (ជាធម្មតាមិនមែនមានតែជាភាសាអង់គ្លេសនោះទេ)។ បន្ថែមពីលើការបញ្ចេញព័ត៌មានអំពីរបាយការណ៍ IEE/EIA ជាភាសាអង់គ្លេសដែលត្រូវបញ្ចេញជាសារជារណៈនៅលើគេហទំព័ររបស់ ADB។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# V. ការអនុវត្ត និងការពិនិត្យតាមដាន

## ក. ការទទួលខុសត្រូវ និងការរៀបចំស្ថាប័ន

២៤. **ការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) ទទួលខុសត្រូវចំពោះទិដ្ឋភាពទូទៅនៃបរិស្ថានរបស់គម្រោងដែលភាគច្រើន** រួមមាន៖ (១). ការអនុវត្តការគ្រប់គ្រងបរិស្ថានរបស់គម្រោងដោយយោងតាមក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) នេះ។ (២). ការត្រួតពិនិត្យការអនុវត្តអនុគម្រោងដោយយោងតាមផែនការគ្រប់គ្រងបរិស្ថាន (EMP) ឬក្រមប្រតិបត្តិបរិស្ថាន (ECOP) របស់ខ្លួន។ (៣). ការតាមដាន និងការរាយការណ៍អំពីវឌ្ឍភាពគម្រោងទៅកាន់ភ្នាក់ងារប្រតិបត្តិគម្រោង (EA) និងទៅកាន់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង (៤). ការតាមដានលើអនុលោមភាពនៃការពារបរិស្ថាន។

២៥. <u>**បុគ្គលិកការពារសុវត្ថិភាពបរិស្ថានដែលបានតែងតាំង ឬជនបង្គោលនៃការិយាល័យ NPMO**</u> ត្រូវធ្វើការសម្របសម្រួលលើការគ្រប់គ្រងបរិស្ថានរបស់គម្រោង ដោយយោងតាមក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF) នេះ និងផែនការគ្រប់គ្រងបរិស្ថាន (EMP) នៃអនុគម្រោង។ បុគ្គលិករូបនេះ ត្រូវទទួលបន្ទុកលើការតាមដាន និងការត្រួតពិនិត្យបរិស្ថាន និងធ្វើរបាយការណ៍ពាក់កណ្ដាលឆ្នាំស្ដីពីលទ្ធផលនៃការអនុវត្តកិច្ចការងារបរិស្ថានទៅកាន់ភ្នាក់ងារប្រតិបត្តិគម្រោង (EA) និងទៅកាន់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

២៦. <u>**អង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIUs)**</u> ដែលជាខ្សែបណ្ដោយទីមួយនៃការគ្រប់គ្រង ត្រូវទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន (EMP) ដោយអ្នកម៉ៅការ ឬប្រតិបត្តិករនៃអនុគម្រោងរបស់ខ្លួន។ ការិយាល័យ NPMO ដោយមានជំនួយពីទីប្រឹក្សាអនុវត្តគម្រោង (PIC) នឹងត្រូវមានតួនាទីជាខ្សែបណ្ដោយទីពីរនៃការតាមដាន និងការត្រួតពិនិត្យ។

២៧. <u>**ម្ចាស់អនុគម្រោង**</u> (អាចជាអង្គភាព PPIUs ក្នុងស្រុក ឬអង្គភាពផ្សេងទៀត) ត្រូវទទួលខុសត្រូវចំពោះអនុលោមភាពនៃលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន សុខភាព និងសុវត្ថិភាពដែលអាចអនុវត្តបានទាំងក្នុងស្រុក និងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តាមរយៈការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន (EMP) ក្នុងចំណោមផែនការដទៃទៀត។ នៅទីបញ្ចប់ ផែនការ EMP នៃអនុគម្រោងនីមួយៗចាំបាច់ត្រូវបញ្ចូលក្នុងឯកសារដេញថ្លៃ និងកិច្ចសន្យាជាមួយអ្នកម៉ៅការសម្រាប់ការងារសាងសង់ និងជាមួយប្រតិបត្តិករសម្រាប់ការងារប្រតិបត្តិការ និងការថែទាំ (O&M)។

២៨. <u>**អ្នកជំនាញបរិស្ថានដែលជាទីប្រឹក្សាអនុវត្តគម្រោង (PIC)**</u> ត្រូវជួយដល់ការិយាល័យ NPMO ក្នុងការបំពេញភារកិច្ចការពារបរិស្ថានទាំងអស់ ដូចដែលបានពិពណ៌នានៅក្នុង EARF នេះ និង EMP របស់អនុគម្រោង ក៏ដូចជានៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចី។ ការជួយគាំទ្របែបនេះ ត្រូវតែរួមបញ្ចូលការផ្ដល់ការបណ្ដុះបណ្ដាលដល់ NPMO/PPIU និងអ្នកម៉ៅការលើការអនុវត្ត EARF សម្រាប់អនុគម្រោងប្រភេទ C និង EMP សម្រាប់អនុគម្រោងប្រភេទ B ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

## ខ. លក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យ និងការរាយការណ៍

២៩. ចំពោះអនុគម្រោងប្រភេទ C មិនតម្រូវឱ្យមានការត្រួតពិនិត្យជាប្រចាំនៅនឹងកន្លែងនោះទេ។ ផ្ទុយទៅវិញអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIU) អាចធ្វើការពិនិត្យតាមដានដោយចៃដន្យលើការប្រកាន់ខ្ជាប់នូវលក្ខខណ្ឌនៃក្របខ័ណ្ឌត្រួតពិនិត្យការវាយតម្លៃបរិស្ថាន (EARF)។ ប្រសិនបើអនុគម្រោង ត្រូវបានរកឃើញថាមិនអនុវត្តតាមក្រមប្រតិបត្តិបរិស្ថាន (ECOP) ទេនោះ អង្គភាព PPIUs គួរតែចុះត្រួតពិនិត្យផ្ទាល់ជាទៀងទាត់បន្ថែមទៀត រហូតដល់ការអនុវត្តអនុគម្រោងនោះត្រូវបានធ្វើឱ្យប្រសើរឡើង។

៣០. ចំពោះអនុគម្រោងប្រភេទ B វិញ NPMO/PPIUs ដោយមានជំនួយពីអ្នកជំនាញបរិស្ថានដែលជាទីប្រឹក្សាអនុវត្តគម្រោង (PIC) គួរតែចុះពិនិត្យផ្ទាល់នៅតាមទីតាំងអនុគម្រោងយ៉ាងហោចណាស់ឱ្យបានពីរដងក្នុងមួយឆ្នាំ។ លើសពីនេះទៀត ការត្រួតពិនិត្យប្រចាំថ្ងៃលើការអនុវត្ត EMP អំឡុងពេលសាងសង់ (ឧ. ការកសាងហេដ្ឋារចនាសម្ព័ន្ធរបស់អនុគម្រោង) គួរតែត្រូវបានអនុវត្តដោយវិស្វករត្រួតពិនិត្យការសាងសង់។ ប្រសិនបើវិស្វករត្រួតពិនិត្យមិនត្រូវបានចាត់តាំងទេនោះ វិស្វករដែលនៅនឹងកន្លែង (ឧ. ស្នាក់នៅកន្លែងការដ្ឋាន) គួរតែអនុវត្តមុខងារនេះ។ ក្នុងអំឡុងពេលប្រតិបត្តិការនៃអនុគម្រោង អង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIU) គួរតែចុះពិនិត្យផ្ទាល់នៅទីតាំងជាទៀងទាត់ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីអ្វីដែលប្រតិបត្តិករអនុគម្រោងបានរាយការណ៍ដោយខ្លួនឯង និងដោយពេញចិត្ត (ឧ. ទីសត្តឃាត ជាដើម)។

៣១. ការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) ដោយមានជំនួយពីទីប្រឹក្សាអនុវត្តគម្រោង (PIC) ត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ពាក់កណ្ដាលឆ្នាំស្ដីពីលទ្ធផលនៃការអនុវត្តអនុគម្រោង សម្រាប់ដាក់ជូនទៅកាន់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ខ្លឹមសាររបាយការណ៍ គួរតែត្រូវបានចងក្រងចេញពីរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាសដែលរៀបចំដោយ POAHP/PPIU។

## គ. ការប្រែប្រួលនៃអនុគម្រោង និងការមិនអនុលោមតាម

៣២. ក្នុងអំឡុងពេលកិច្ចសន្យានៃអនុគម្រោង ការប្រែប្រួលណាមួយចំពោះការរចនាអនុគម្រោង ដែលអាចបង្កឱ្យមានផលប៉ះពាល់បរិស្ថានអវិជ្ជមានបន្ថែម ឬកើនឡើង នឹងត្រូវពិនិត្យពិច័យដោយអ្នកជំនាញបរិស្ថានការិយាល័យ NPMO និង PIC និងតាមភាពសមស្របរបស់ ADB ដើម្បីវាយតម្លៃថាតើការប្រែប្រួលបែបនេះចាំបាច់តម្រូវឱ្យមានវិធានការកាត់បន្ថយ និងការត្រួតពិនិត្យបន្ថែម ឬប៉ះពាល់ដល់ការចាត់ថ្នាក់ប្រភេទនៃការពារបរិស្ថានរបស់អនុគម្រោងដែរឬអត់។

៣៣. សេណារីយ៉ូមួយក្នុងចំណោមសេណារីយ៉ូទាំងបី នឹងត្រូវអនុវត្តប្រសិនបើការប្រែប្រួលដែលបានស្នើឡើងរបស់អនុគម្រោង អាចបណ្ដាលឱ្យមានផលប៉ះពាល់បរិស្ថានបន្ថែម ឬសំខាន់ជាងនេះ៖ (១). ចំពោះអនុគម្រោងប្រភេទ C ដែលស្ថិតនៅក្រោមក្របខ័ណ្ឌ EARF អនុគម្រោងនឹងត្រូវចាត់ថ្នាក់ឡើងវិញថាជាប្រភេទ B ហើយចាំបាច់ត្រូវរៀបចំឱ្យមាន IEE និង EMP។ (២). វិធានការកាត់បន្ថយដែលមានចែងក្នុងអនុគម្រោងប្រភេទ B គឺត្រូវតែកែសម្រួល ឬកែប្រែតាមការចាំបាច់ចំពោះផែនការគ្រប់គ្រងបរិស្ថាន។ ឬ (៣). ការផ្លាស់ប្ដូរទៅជាអនុគម្រោងប្រភេទ B ដែលបណ្ដាលឱ្យមានផលប៉ះពាល់បរិស្ថានសំខាន់ៗ គឺចាំបាច់ត្រូវចាត់ថ្នាក់ឡើង



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

វិញថាជាប្រភេទ A ដែលនឹងធ្វើឱ្យអនុគម្រោងនេះលែងមានសិទ្ធិទទួលបានមូលនិធិគម្រោងទៀតហើយ។

៣៤. ក្នុងករណីដែលអនុគម្រោងមិនអនុលោមតាម EARF ឬ EMP ដូចដែលបានអនុញ្ញាតសម្រាប់អនុគម្រោងជាក់លាក់ណាមួយ នីតិវិធីខាងក្រោមនឹងត្រូវអនុវត្តៈ

(១). NPMO និង PPIU ដោយមានជំនួយពី PIC ត្រូវណែនាំដល់អនុគម្រោងដែលមិនអនុលោមនោះឱ្យធ្វើការដោះស្រាយចំពោះការរំលោភបំពានក្នុងរយៈពេលកំណត់ដោយចំណាយផ្ទាល់ខ្លួន។ ការិយាល័យNPMO និងអង្គភាព PPIU នឹងពិនិត្យតាមដានលើអនុគម្រោងនោះ ដើម្បីបញ្ជាក់ថាតើបញ្ហាមិនអនុលោមតាមនេះ ត្រូវបានដោះស្រាយដោយការពេញចិត្តឬអត់។

(២). ក្នុងករណីដែលការមិនអនុលោមតាមនោះមានលក្ខណៈធ្ងន់ធ្ងរ (ឧ. បណ្តាលឱ្យមានការតវ៉ាជាសាធារណៈ ឬបណ្តាលឱ្យខូចគុណភាពទឹកលើដី) ការិយាល័យ NPMO និងអង្គភាព PPIU នឹងទទួលបានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីការិយាល័យគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានខេត្ត (PONRE) ថាបញ្ហាមិនអនុលោមតាមនេះ គឺត្រូវបានដោះស្រាយដោយការពេញចិត្ត។

(៣). ប្រសិនបើអនុគម្រោង មិនទាន់បានកែតម្រូវចំពោះបញ្ហាមិនអនុលោមតាមនេះឱ្យបានគ្រប់គ្រាន់ក្នុងរយៈពេលកំណត់ទេនោះ អនុគម្រោងនោះនឹងត្រូវផ្អាក ហើយត្រូវតែអនុវត្តតាមដំណោះស្រាយដែលអនុញ្ញាត (ឧ. ការពិន័យតាមកិច្ចសន្យា)។

(៤). ក្នុងករណីមានការមិនអនុលោមតាម និងការបរាជ័យនៃអនុគម្រោងក្នុងការកែតម្រូវចំពោះបញ្ហាណាមួយដោយពេញចិត្តនោះ ការិយាល័យ NPMO នឹងជូនដំណឹងភ្លាមៗដល់ MAFF/ADB អំពីបញ្ហាមិនអនុលោមតាមនេះ និងស្នើចាត់វិធានការ។

## ឃ. ការពិគ្រោះយោបល់ជាសាធារណៈ និងការបញ្ចេញព័ត៌មាន

៣៥. ការពិគ្រោះយោបល់ជាសាធារណៈ ត្រូវរួមបញ្ចូលការពិភាក្សាជាមួយក្រុមអ្នកទទួលផលនៃអនុគម្រោងអ្នកដែលរងផលប៉ះពាល់ពីអនុគម្រោង និងអាជ្ញាធរឃុំ ដែលជាផ្នែកមួយនៃការរៀបចំការត្រួតពិនិត្យបរិស្ថានបឋម (IEE) ដើម្បីកំណត់ឱ្យឃើញពីក្តីកង្វល់ណាមួយដែលអាចនឹងត្រូវដោះស្រាយ។ នីតិវិធីពិគ្រោះយោបល់គួរតែបំពេញតាមកម្រិតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងលក្ខខណ្ឌតម្រូវនៃសេចក្តីថ្លែងគោលនយោបាយបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB-SPS)។ ព័ត៌មានដែលបានផ្តល់ឱ្យក្នុងអំឡុងពេលពិគ្រោះយោបល់ គួរតែមានរួមបញ្ចូលសេចក្តីសង្ខេបនេះ សកម្មភាពការងាររបស់អនុគម្រោង ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានចំពោះបរិស្ថានក្នុងអំឡុងពេលសាងសង់ និងដំណាក់កាលរចនាប្លង់ ក៏ដូចជាវិធានការបញ្ចៀស និងកាត់បន្ថយដែលបានគ្រោងទុក។

៣៦. កាលបរិច្ឆេទ អ្នកចូលរួម ប្រធានបទដែលត្រូវលើកយកមកពិគ្រោះយោបល់ និងការសន្និដ្ឋានចុងក្រោយលើមតិកែលម្អដែលបានផ្តល់ឱ្យ គួរតែត្រូវបានកត់ត្រាទុក និងសង្ខេបនៅក្នុងរបាយការណ៍ IEE ។ របាយការណ៍ចុងក្រោយនៃ IEE គួរតែត្រូវបានធ្វើឡើងជាភាសាអង់គ្លេស និងជាភាសាខ្មែរ ដើម្បីឱ្យសាធារណជន



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

ទូទៅអាចពិនិត្យមើលបាន។ របាយការណ៍ IEE ទាំងអស់នឹងត្រូវដាក់ជូនធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីបង្ហោះនៅលើគេហទំព័ររបស់ ADB។

## ខ. យន្តការបណ្តឹងសាទុក្ខ (បណ្តឹងតវ៉ា)

៣៧. ការិយាល័យជាតិគ្រប់គ្រងគម្រោង (NPMO) ត្រូវបង្កើតយន្តការដោះស្រាយបណ្តឹងសាទុក្ខ (GRM) ដោយមាន កិច្ចសម្របសម្រួលជាមួយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIU) សំដៅធានាបាននូវការដោះស្រាយឱ្យបានទាន់ពេលវេលាចំពោះការប្តឹងតវ៉ាទាំងឡាយណាដែលធ្វើឡើងដោយសហគមន៍ និងអ្នកដែលរងផលប៉ះពាល់ជុំវិញការសាងសង់ និងប្រតិបត្តិការរបស់អនុគម្រោង។ យន្តការ GRM គួរតែអាចចូលបានដោយទូលំទូលាយសម្រាប់សហគមន៍ រួមទាំងស្ត្រី យុវជន និងជាពិសេសក្រុមងាយរងគ្រោះ។ ការចូលរួមនេះ នឹងធ្វើឡើងតាមរយៈមធ្យោបាយជាច្រើនដូចជា ការប្រជុំទល់មុខគ្នា ការតវ៉ាជាលាយលក្ខណ៍អក្សរ ការសន្ទនាតាមទូរស័ព្ទ ឬអ៊ីមែល ជាដើម។ បុគ្គលរងផលប៉ះពាល់ដែលដាក់ពាក្យបណ្តឹងតវ៉ា អាចមានបំណងចង់លើកឡើងនូវកង្វល់របស់ខ្លួនជាលក្ខណៈរក្សាការសម្ងាត់។ ប្រសិនបើអ្នកប្តឹងតវ៉ាស្នើសុំឱ្យលាក់អត្តសញ្ញាណរបស់ពួកគេ នោះគេត្រូវតែធ្វើតាមសំណូមពរនេះ ហើយមិនត្រូវបង្ហាញអត្តសញ្ញាណរបស់ពួកគេដោយគ្មានការយល់ព្រមជាមុននោះទេ។ នីតិវិធីសម្រាប់យន្តការបណ្តឹងសាទុក្ខ (GRM) មានដូចតទៅ៖

(១). បណ្តឹងសាទុក្ខ អាចត្រូវបានធ្វើឡើងដោយបុគ្គល គ្រួសារ ឬសហគមន៍ ទៅតាមប្រភេទនៃពាក្យបណ្តឹង។ បុគ្គលអ្នកប្តឹងត្រូវទៅជួបមេភូមិជាមុនសិន ដើម្បីពន្យល់បញ្ជាក់ពីបញ្ហា។ បន្ទាប់មកមេភូមិនឹងពិនិត្យពាក្យបណ្តឹង ហើយដោះស្រាយឡើងវិញនៅថ្នាក់ភូមិ ឬបញ្ជូនទៅអាជ្ញាធរថ្នាក់លើ ប្រសិនបើនៅតែមិនអាចដោះស្រាយបាន។ មេភូមិនឹងជួយសម្រួលក្នុងការបំពេញទម្រង់បែបបទដាក់ពាក្យបណ្តឹងដោយពណ៌នាឱ្យបានច្បាស់លាស់អំពីមូលហេតុនៃបញ្ហា និងដំណោះស្រាយដែលអាចធ្វើទៅបានតាមការចង់បាន។ ក្រោយបញ្ចប់រួចរាល់ហើយ ភាគីទាំងពីរនឹងត្រូវចុះហត្ថលេខាលើទម្រង់បែបបទនោះ។

(២). បន្ទាប់ពីបំពេញបែបបទដាក់ពាក្យបណ្តឹងរួច ច្បាប់ចម្លងមួយច្បាប់នឹងត្រូវដំកល់ទុកនៅការិយាល័យមេភូមិ ច្បាប់ចម្លងមួយច្បាប់ទៀតត្រូវប្រគល់ឱ្យបុគ្គលអ្នកប្តឹង និងច្បាប់ចម្លងមួយច្បាប់ទៀតត្រូវដាក់ជូន DOAHP ។ ក្នុងរយៈពេលដប់ប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានពាក្យបណ្តឹងជាផ្លូវការ មេភូមិ និង DOAHP អមដោយអ្នកឯកជំនាញដែលពាក់ព័ន្ធ នឹងចុះទៅសួរនាំផ្ទាល់ជាមួយបុគ្គលអ្នកប្តឹង ដើម្បីស្វែងរកមូលហេតុនៃបញ្ហា និងយល់ព្រមលើការស្វែងរកដំណោះស្រាយ។ ប្រសិនបើអាចឈានទៅដល់ដំណោះស្រាយណាមួយ ភាគីពាក់ព័ន្ធទាំងអស់នឹងត្រូវចុះហត្ថលេខាលើទម្រង់បែបបទនោះ។

(៣). ក្នុងករណីដែលបុគ្គលកអ្នកប្តឹងមិនពេញចិត្តនឹង DOAHP ក្នុងការដោះស្រាយបណ្តឹងតវ៉ានោះ ពាក្យបណ្តឹងនោះនឹងត្រូវដាក់ជូន PPIU/POAHP ដើម្បីដោះស្រាយក្នុងរយៈពេលដប់ថ្ងៃនៃថ្ងៃធ្វើការ។ ប្រសិនបើឈានដល់ដំណោះស្រាយណាមួយ ភាគីពាក់ព័ន្ធទាំងអស់នឹងត្រូវចុះហត្ថលេខាលើទម្រង់បែបបទនោះ។

(៤). ប្រសិនបើដំណោះស្រាយចុងក្រោយ នៅតែមិនអាចទទួលយកបានសម្រាប់បុគ្គលអ្នកប្តឹង ត្រូវបន្តដាក់ពាក្យបណ្តឹងនោះទៅកាន់តុលាការ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

(៥). បុគ្គលអ្នកប្តឹង ក៏អាចជ្រើសរើសវិធីទាក់ទងការិយាល័យ ADB ប្រចាំប្រទេស និង/ឬទាក់ទងទៅផ្នែកយន្តការគណនេយ្យភាពរបស់ ADB [3] ផងដែរ។

(៦). អង្គភាព PPIU អាចទាក់ទងទៅអ្នកប្តឹងតវ៉ានៅដំណាក់កាលក្រោយ ដើម្បីធានាថាពួកគេពិតជាពេញចិត្តចំពោះសកម្មភាពកែតម្រូវដែលបានធ្វើឡើង។ ប្រសិនបើមានបញ្ហាណាមួយនៅសេសសល់នោះនឹងត្រូវបានចាត់ទុកជាបណ្តឹងសាទុក្ខថ្មី ហើយត្រូវអនុវត្តដំណើរការ GRM សារជាថ្មីឡើងវិញ។

(៧). អង្គភាព PPIUs និង NPMO នឹងរក្សាទុកកំណត់ត្រានៃពាក្យបណ្តឹង និងសកម្មភាពដែលបានធ្វើឡើងដើម្បីកែតម្រូវ។ ព័ត៌មាននេះគួរតែត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍របស់ការិយាល័យ NPMO រួចបញ្ជូនទៅកាន់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

[3] យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB ត្រូវបានបង្កើតឡើងដើម្បីផ្តល់ជាវេទិកាឯករាជ្យ និងមានប្រសិទ្ធភាពសម្រាប់អ្នកដែលរងផលប៉ះពាល់ពីគម្រោងផ្តល់ជំនួយរបស់ ADB ដើម្បីបង្ហាញពីកង្វល់របស់ពួកគេ។ ពាក្យបណ្តឹង អាចត្រូវបានបញ្ជូនទៅមន្ត្រីទទួលពាក្យបណ្តឹង (CRO) យន្តការគណនេយ្យភាព៖ amcro@adb.org ។ ម៉្យាងទៀត ពាក្យបណ្តឹងអាចនឹងត្រូវដាក់ជូនតាមរយៈការិយាល័យ ADB ណាមួយ ដូចជាការិយាល័យក្រុមបេសកកម្មប្រចាំប្រទេស ឬការិយាល័យតំណាង ដែលនឹងត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅកាន់មន្ត្រីទទួលពាក្យបណ្តឹង (CRO)។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# ឧបសម្ព័ន្ធ A. ការពិនិត្យដើម្បីចាត់ចំណាត់ថ្នាក់ប្រភេទបរិស្ថាន

## សេចក្តីណែនាំ៖

គោលបំណងនៃការបង្កើតតារាងនេះ គឺដើម្បីប្រមូលព័ត៌មានជាមូលដ្ឋានដែលចាំបាច់ដើម្បីកំណត់ផលប៉ះពាល់បរិស្ថានសក្តានុពលនៃគម្រោងណាមួយ ដែលត្រូវចាត់ថ្នាក់ថាជាគម្រោងប្រភេទ (A, B ឬ C) សម្រាប់ការវាយតម្លៃ និងការគ្រប់គ្រង។ ផ្នែកទី ១ នឹងបង្ហាញពីលក្ខណៈ និងទំហំនៃគម្រោង កត្តាសំខាន់ៗដែលកំណត់ពីផលប៉ះពាល់បរិស្ថាន និងការចាត់ចំណាត់ថ្នាក់ប្រភេទរបស់វា។ ផ្នែកទី ២ នឹងបង្ហាញពីការកំណត់ជ្រើសរើស ដែលជាកត្តាកំណត់ទី ៣ ដែលត្រូវការជាពិសេសនៅពេលដែលប្រភេទនេះហាក់ដូចជាឆ្លងកាត់ប្រភេទដែលវិនិច្ឆ័យដោយផ្អែកពីរពីដំបូង។ លក្ខណៈវិនិច្ឆ័យនៃការចាត់ចំណាត់ថ្នាក់ EIA នៅក្នុងប្រទេសភាគច្រើន គឺពិតជាផ្អែកលើលក្ខណៈ និងទំហំវិសាលភាព ដែលជាមូលដ្ឋាននៃសំណើគម្រោងណាមួយត្រូវតែមាន គួបផ្សំនឹងព័ត៌មានអំពីការជ្រើសរើសទីតាំងរបស់គម្រោងផងដែរ។ ចូរពន្យល់អំពីរបៀបបំពេញក្នុងតារាងត្រង់ចន្លោះដែលមាន *អក្សរទ្រេត*។

## ផ្នែកទី I. លក្ខណៈពិសេសជាមូលដ្ឋាននៃគម្រោង ឬអនុគម្រោង

| |
|---|
| **១. លក្ខណៈនៃសកម្មភាពគម្រោង៖**<br>*(តើគម្រោងនិយាយអំពីអ្វី ឬនៅក្នុងវិស័យ ឬអនុវិស័យណាមួយ? លក្ខណៈពិសេសខាងក្នុងអាចកំណត់បាននូវផលប៉ះពាល់នានា ឧទាហរណ៍៖*<br>• <u>ហេដ្ឋារចនាសម្ព័ន្ធលីនេអ៊ែរ</u>៖ ផ្លូវ ឬបណ្តាញជាពសាស្ត្រ? ថ្មី ឬ ស្តារឡើងវិញ? ប្រសិនបើមានការកែលម្អឡើងវិញ តើមានការពង្រីកអ្វីខ្លះ? តើត្រូវពង្រីកក្នុងទំហំប៉ុន្មាន? តើផលប៉ះពាល់បរិស្ថានពីមុនមានចំនួនច្រើនជាងផលប៉ះពាល់បរិស្ថានចុងក្រោយដែរឬទេ។<br>• <u>ហេដ្ឋារចនាសម្ព័ន្ធមិនមែនលីនេអ៊ែរ</u>៖ កន្លែងចាក់សំរាម ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកង្វក់ (WWTP) ឬរោងចក្រថាមពល? ការដុតធ្យូងថ្មមានផលប៉ះពាល់ធំ និងស្មុគស្មាញជាងឧស្ម័ន ឬជីវម៉ាស់។ ការធ្វើប្រព្រឹត្តកម្មសំរាម គឺមានលក្ខណៈស្មុគ្រស្មាញជាងការធ្វើលើដីល្បាប់។<br>• វិស័យកែច្នៃកសិផល ឬឧស្សាហកម្ម៖ បញ្ជាក់ឱ្យច្បាស់ថាតើអនុវិស័យមួយណា ឬឧស្សាហកម្មណាខ្លះ ដោយសារអនុវិស័យ ឬឧស្សាហកម្មខ្លះបង្កឱ្យមានការបំពុលខ្លាំង និងប្រពលលក្ខណៈផ្នែកថាមពល/ប្រើប្រាស់ទឹក ឧ. ការធ្វើសត្តឃាត និងការសម្លាប់ស្បែក (ឱ្យឡើងពណ៌ជាំដែង) ចំណែកអនុវិស័យ ឬឧស្សាហកម្មខ្លះទៀតមានការបំពុល ឬប៉ះពាល់បរិស្ថានតិចតួចជាងនេះ ដូចជាការកែច្នៃគ្រាប់ធញ្ញជាតិ ប៉ុន្តែផ្នែកខ្លះទៀតស្ថិតនៅក្នុងកម្រិតប៉ះពាល់មធ្យម ដូចជាការផលិតកែច្នៃទឹកដោះគោដែលអាចបរិភោគបាន ការផលិតកែច្នៃប្រេង និងទឹកផ្លែឈើ ជាដើម។<br>• *សម្រាប់វិស័យ/បែបបទវិនិយោគ FI, RBL ឬ PBL៖* តើវិស័យ ឬអនុវិស័យអ្វីខ្លះដែលគ្រោងនឹងគ្របដណ្តប់? |
| **២. ទំហំនៃសកម្មភាពគម្រោង៖**<br>*(សមត្ថភាពដែលបានរចនា ឬសមត្ថភាពជាក់ស្តែង ឧ. ប្រវែងផ្លូវ ឬប្រឡាយដែលបានស្នើឡើង? ទំហំទីតាំង* |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| |
|---|
| *គ្រប់គ្រង (ហិកតា) តើស្ថានីយ៍ប្រព្រឹត្តកម្មទឹកកង្វក់ (WWTP) អាចធ្វើប្រព្រឹត្តកម្មទឹកបានប៉ុន្មានម៉ែត្រគូបក្នុងមួយថ្ងៃ? តើមានប៉ុន្មានតោនក្នុងថ្ងៃ សម្រាប់ការចាក់សំរាម ឬដុតសំរាម, ចំនួនសត្វក្នុងមួយកសិដ្ឋាន ឬក្នុងមួយថ្ងៃសម្រាប់ការផលិត និងកែច្នៃ។ ទិន្នន័យទាំងនេះ មានសារៈសំខាន់សម្រាប់ការវិនិច្ឆ័យ និងការផ្ទៀងផ្ទាត់ ពីព្រោះនៅក្នុងវង្វង់ឧស្សាហកម្មណាមួយ ឬវិស័យណាមួយ ទំហំនៃសកម្មភាពអាចកំណត់ឱ្យដឹងពីទំហំនៃផលប៉ះពាល់។ សម្រាប់វិស័យ/បែបបទវិនិយោគ FI, RBL ឬ PBL៖* បង្ហាញពីទំហំដែលអាចដឹងជាមុនសម្រាប់វិស័យ ឬអនុវិស័យនីមួយៗដែលគ្របដណ្តប់)។ |
| **៣. តម្រូវការអនុលោមភាពបរិស្ថានក្នុងស្រុកដែលអាចអនុវត្តបាន។**<br>*(ប្រៀបធៀបព័ត៌មានដែលប្រមូលបានពីក្នុងផ្នែក ១-២ ខាងលើ រួមជាមួយនឹងលក្ខណៈវិនិច្ឆ័យនៃការចាត់ថ្នាក់ EIA ក្នុងប្រទេស ដោយផ្អែកលើកម្រិតទំហំតាមវិស័យ ឬអនុវិស័យនីមួយៗ។ សម្រាប់សកម្មភាពដែលមិនត្រូវបានគ្របដណ្តប់ក្នុងវិធានក្នុងប្រទេស សូមពិគ្រោះជាមួយអាជ្ញាធរបរិស្ថានពាក់ព័ន្ធអំពីប្រភេទក្នុងស្រុក និងលក្ខខណ្ឌតម្រូវនៃ EIA ដែលពាក់ព័ន្ធ ក៏ដូចជាការយល់ព្រម ឬការអនុញ្ញាតផ្សេងទៀតដែលត្រូវការជាចាំបាច់នៅក្នុងប្រទេស។ នេះក៏ជាឯកសារយោងសម្រាប់ការវិនិច្ឆ័យរបស់អ្នកផងដែរ។)* |
| **ព័ត៌មានផ្សេងទៀតដែលអាចជួយវិនិច្ឆ័យផលប៉ះពាល់ ឬហានិភ័យ (ឬចំណាត់ថ្នាក់ប្រភេទ):** *(ឧ. សមត្ថភាពរបស់ភាគីដែលជាម្ចាស់ក្នុងការគ្រប់គ្រងបរិស្ថាន ការកត់ត្រាការតាមដានរបស់ពួកគេ។ល។)* |

## ផ្នែកទី II. ការកំណត់ទីតាំងគម្រោង ឬអនុគម្រោងដែលត្រូវបានស្នើឡើង

| រួមបញ្ចូលមជ្ឈដ្ឋានដែលទទួលរងឥទ្ធិពល និង/ឬតំបន់ការពារផ្សេងៗ ប៉ុន្តែមិនត្រូវបានកំណត់ឡើងចំពោះ៖ | ប្រសិនបើស្ថិតនៅក្នុងតំបន់ទាំងនេះ សូមផ្តល់ព័ត៌មានលម្អិត | ប្រសិនបើស្ថិតនៅខាងក្រៅ តើត្រង់កន្លែងណា និងចម្ងាយប៉ុន្មានពីព្រំប្រទល់របស់ខ្លួន? |
|---|---|---|
| ជម្រកសំខាន់ និងជម្រកធម្មជាតិ ដូចដែលបានកំណត់ដោយ SPS តំបន់បេតិកភណ្ឌធម្មជាតិពិភពលោក ឬតំបន់បេតិកភណ្ឌវប្បធម៌ ដែលបានកំណត់រួចជាផ្លូវការ ឧទ្យានព្រៃឈើ ឧទ្យានភូមិសាស្ត្រ តំបន់ដីសើមសំខាន់ៗ ដែនជម្រកសំខាន់ៗសម្រាប់សត្វព្រៃ តំបន់បន្តពូជនៃប្រភេទរុក្ខជាតិដែលត្រូវការពារ ការពងកូន ការចិញ្ចឹម តំបន់ដីរដូវសន្សើម និងផ្លូវចរាចរសម្រាប់ប្រភេទសត្វរស់នៅក្នុងទឹកសំខាន់ៗ តំបន់ជោរ | | |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| | | |
|---|---|---|
| នាច ព្រៃកោងកាង ជាដើម តំបន់ការពារទោះជាមិនទាន់បានកំណត់ជាផ្លូវការដោយរដ្ឋ ប៉ុន្តែត្រូវបានទុកថាសំខាន់ជាអន្តរជាតិ ដូចជាត្រូវបានកំណត់ដោយអង្គការ IUCN, UNEP ជាដើម។ | | |
| ដីស្រែមូលដ្ឋាន ឬដីស្មៅមូលដ្ឋានដែលបានកំណត់ទុក តំបន់ទេសភាព/សួនឧទ្យាន តំបន់ការពារប្រភពទឹកផឹក តំបន់ការពារពិសេសមហាសមុទ្រ តំបន់នេសាទធម្មជាតិ តំបន់សំខាន់សម្រាប់ការគ្រប់គ្រងទឹក និងសំណឹកដី តំបន់បិទទុកសម្រាប់វាលរហោឋាន។ល។ | | |
| តំបន់ដែលមានមុខងារសំខាន់ដូចជាលំនៅដ្ឋាន សុខាភិបាល និងវេជ្ជសាស្ត្រ វប្បធម៌ ការអប់រំ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការិយាល័យ ព្រមទាំងធនធានវប្បធម៌រូបវន្ត/កេរតំណែលបុរាណ អាកាសយានដ្ឋាន វាលទំពអាកាស ឬមូលដ្ឋាន/តំបន់យោធា។ល។ | | |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

## ឧបសម្ព័ន្ធ B. បញ្ជីសកម្មភាពវិនិយោគដែលត្រូវហាមឃាត់របស់ ADB

សកម្មភាពខាងក្រោមនេះ មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការទទួលហិរញ្ញប្បទានពី ADB៖

១. ការផលិត ឬសកម្មភាពដែលពាក់ព័ន្ធនឹងទម្រង់បង្គគ្រោះថ្នាក់ ឬកេងប្រវ័ញ្ចនៃពលកម្មដោយបង្ខំ[4] ឬពលកម្មកុមារ [5]។

២. ការផលិត ឬធ្វើពាណិជ្ជកម្មលើផលិតផល ឬសកម្មភាពណាមួយដែលត្រូវបានចាត់ទុកថាល្មើច្បាប់ក្រោមច្បាប់ ឬបទប្បញ្ញត្តិរបស់ប្រទេសម្ចាស់ផ្ទះ ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ឬជាកម្មវត្ថុនៃដំណាក់កាលចេញ ឬបម្រាមអន្តរជាតិ ដូចជា (ក). ឱសថ[6] ថ្នាំសម្លាប់សត្វល្អិត និងថ្នាំបាញ់ស្មៅ[7], (ខ). សារជាតុបំផ្លាញអូហ្សូន [8], (គ) ប៊ីផេនីលប៉ូលីក្លរ (polychlorinated biphenyls)[9] និងសារជាតុគីមីគ្រោះថ្នាក់ផ្សេងទៀត[10], (ឃ) សត្វព្រៃ ឬផលិតផលសត្វព្រៃដែលគ្រប់គ្រងក្រោមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ សត្វព្រៃ និងរុក្ខជាតិជិតផុតពូជ[11] និង (ង). ពាណិជ្ជកម្មឆ្លងដែនលើកាកសំណល់ ឬផលិតផលកាកសំណល់ [12]។

៣. ការផលិត ឬជួញដូរអាវុធ និងសព្វាវុធ រួមទាំងសម្ភារៈយោធាប្រតិព័ន្ធ។

៤. ការផលិត ឬជួញដូរភេសជ្ជៈមានជាតិអាល់កុល ដោយមិនរាប់បញ្ចូលស្រាបៀរ និងស្រា[13]។

៥. ការផលិត ឬពាណិជ្ជកម្មថ្នាំជក់។

៦. ល្បែងស៊ីសង កាស៊ីណូ និងសហគ្រាសដែលមានតម្លៃស្មើ។

---

[4] ពលកម្មដោយបង្ខំ មានន័យថារាល់ការងារ ឬសេវាកម្មទាំងអស់ ដែលមិនត្រូវបានអនុវត្តដោយស្ម័គ្រចិត្ត ពោលគឺការទទួលកាតព្វកិច្ចចេញពីបុគ្គល ដោយស្ថិតនៅក្រោមការគំរាមកំហែងដោយបង្ខំ ឬដោយពិន័យ។

[5] ពលកម្មកុមារ មានន័យថាការងាររបស់កុមារដែលមានអាយុកំណត់តិចជាងអាយុអប្បបរមានៃការងារដែលអនុញ្ញាតក្នុងប្រទេសម្ចាស់ផ្ទះ ឬការងាររបស់កុមារដែលផ្ទុយនឹងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៣៨ "អនុសញ្ញាស្តីពីអាយុអប្បបរមា" (www.ilo.org)

[6] បញ្ជីផលិតផលឱសថដែលស្ថិតក្រោមការផ្អាក ឬហាមប្រាមមាននៅ http://www.who.int

[7] បញ្ជីថ្នាំសម្លាប់សត្វល្អិត និងថ្នាំបាញ់ស្មៅដែលស្ថិតក្រោមដំណាក់កាលផ្អាក ឬហាមប្រាមមាននៅ http://www.pic.int

[8] បញ្ជីសមាសធាតុគីមីដែលមានប្រតិកម្ម និងបំផ្លាញស្រទាប់អូហ្សូនស្រ្តាតូស្ពែរ ដែលបណ្តាលឱ្យកើតមានរន្ធអូហ្សូនដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងស្ថិតក្នុងបញ្ជីនៃពិធីសារម៉ុងរ៉េអាល់ រួមជាមួយនឹងគោលដៅកាត់បន្ថយ និងកាលបរិច្ឆេទក្នុងការផ្អាក។ ព័ត៌មាននេះមាននៅ http://www.unep.org/ozone/montreal.shtml

[9] ក្រុមសារជាតុគីមីពុលខ្លាំង សារជាតុប៊ីផេនីលប៉ូលីក្លរ (polychlorinated biphenyls) ទំនងជាត្រូវបានរកឃើញនៅក្នុងម៉ាស៊ីនបំប្លែងអគ្គិសនីដែលបំពេញដោយថាមពលប្រេង កុងទ័រ និងកុងតាក់ដែលមានអាយុកាលតាំងពីឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៨៥។

[10] ក្រុមសារជាតុគីមីពុលខ្លាំង សារជាតុប៊ីផេនីលប៉ូលីក្លរ (polychlorinated biphenyls) ទំនងជាត្រូវបានរកឃើញនៅក្នុងម៉ាស៊ីនបំប្លែងអគ្គិសនីដែលបំពេញដោយថាមពលប្រេង កុងទ័រ និងកុងតាក់ដែលមានអាយុកាលតាំងពីឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៨៥។

[11] បញ្ជីឈ្មោះប្រភេទសត្វ និងរុក្ខជាតិទាំងនេះ អាចរកបាននៅ http://www.cites.org

[12] ដូចដែលបានកំណត់ដោយអនុសញ្ញាបាសែល; សូមមើលលើគេហទំព័រ៖ http://www.basel.int

[13] នេះមិនអនុវត្តចំពោះអ្នកឧបត្ថម្ភគម្រោងដែលមិនបានចូលរួមពាក់ព័ន្ធធំដុំ ក្នុងសកម្មភាពទាំងនេះទេ។ ការមិនជាប់ពាក់ព័ន្ធធំដុំមានន័យថា សកម្មភាពដែលពាក់ព័ន្ធគឺគ្រាន់តែជាការជួយគាំទ្របន្ថែមសម្រាប់ប្រតិបត្តិការចម្បងរបស់អ្នកឧបត្ថម្ភគម្រោងប៉ុណ្ណោះ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

៧. ការផលិត ឬពាណិជ្ជកម្មលើវត្ថុធាតុវិទ្យុសកម្ម [14] រួមទាំងម៉ាស៊ីនរ៉េអាក់ទ័រនុយក្លេអ៊ែរ និងសមាសធាតុរបស់វា។
៨. ការផលិត ជួញដូរ ឬប្រើប្រាស់សរសៃអាបស្តូសគ្មានដែនកំណត់[15]។
៩. ប្រតិបត្តិការកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម ឬការទិញឧបករណ៍កាប់ឈើសម្រាប់ប្រើប្រាស់ក្នុងព្រៃសើមត្រូពិចបឋម ឬព្រៃលូតលាស់ចាស់។ និង
១០. ការប្រកបរបរនេសាទតាមសមុទ្រ និងតាមឆ្នេរ ដូចជាការនេសាទត្រីដោយប្រើអួនខ្នាតធំ និងការនេសាទដោយប្រើសំណាញ់ល្អិត ដែលបង្កគ្រោះថ្នាក់ដល់ប្រភេទសត្វដែលងាយរងគ្រោះ និងត្រូវបានការពារក្នុងចំនួនដ៏ច្រើន និងធ្វើឱ្យខូចខាតដល់ជីវចម្រុះ និងជម្រកសត្វសមុទ្រ។

[14] នេះមិនអនុវត្តចំពោះការទិញឧបករណ៍វេជ្ជសាស្ត្រ ឧបករណ៍ត្រួតពិនិត្យគុណភាព (រង្វាស់) និងឧបករណ៍ណាមួយដែល ADB ចាត់ទុកថាប្រភពវិទ្យុសកម្មសាមញ្ញធម្មតា និងមានរបាំងការពារគ្រប់គ្រាន់។

[15] នេះមិនអនុវត្តចំពោះការទិញ និងការប្រើប្រាស់សន្លឹកក្រាល ឬដំបូលស៊ីម៉ងត៍អាបស្តូសដែលមានសមាធាតុអាបស្តូសតិចជាង ២០% ទេ។



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# ឧបសម្ព័ន្ធ C. ក្រមបរិស្ថាននៃការអនុវត្តសម្រាប់ការសាងសង់

**ចំណាំ៖** អ្នកអនុវត្តវិធានការទាំងអស់ គឺសំដៅលើអ្នកម៉ៅការ និងកម្មករនយោជិតរបស់ពួកគេ។ ការត្រួតពិនិត្យជាប្រចាំ គឺភាគច្រើនធ្វើឡើងដោយវិស្វករត្រួតពិនិត្យ (ជាអ្នកស្នាក់នៅទីតាំងផ្ទាល់) ដែលសន្មត់ថានឹងត្រូវមានវត្តមាននៅទីតាំងជាប្រចាំថ្ងៃ ហើយពួកគេមានកាតព្វកិច្ចត្រួតពិនិត្យលើកិច្ចការពាក់ព័ន្ធនឹងទិដ្ឋភាពបរិស្ថាន សុខភាព និងសុវត្ថិភាព (EHS) ផងដែរ។ លើសពីនេះអង្គភាព PPIUs/PMUs ដោយមានជំនួយពីបុគ្គលិកផ្នែកបរិស្ថាន ត្រូវចុះតាមដាន និងត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែង។

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
| --- | --- | --- |
| ជារួម, អំឡុងពេលមុនសាងសង់ | ការដេញថ្លៃ និងកិច្ចសន្យា | ១. អនុលោមតាមច្បាប់ទាំងអស់ដែលកំណត់ដោយរដ្ឋាភិបាល។<br>២. បញ្ជាក់ការយល់ព្រមពីរដ្ឋាភិបាល និងលិខិតជានាការអនុញ្ញាតចាំបាច់, ការជម្រះ។<br>៣. អង្គភាព PMUs ត្រូវធានាថាផែនការ EMP ត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃ ក៏ដូចជានៅក្នុងកិច្ចសន្យាការងារសាងសង់។<br>៤. ឯកសារដេញថ្លៃត្រូវរួមបញ្ចូលលើមុខចំណាយ (item) ដោយការបូកសរុបតម្លៃ "វិធានការកាត់បន្ថយបរិស្ថាន"។ ចំណុចនេះត្រូវបានបញ្ជាក់នៅក្នុងឯកសារដាក់លាក់ថា វិធានការដែលអាចអនុវត្តបាននៅក្នុង ECOP និង EMP នឹងត្រូវគិតថ្លៃចំពោះមុខចំណាយនេះ។ ការបញ្ជាក់នេះ នឹងអនុញ្ញាតឱ្យវិស្វករត្រួតពិនិត្យសំណង់តម្រូវឱ្យអ្នកម៉ៅធ្វើការដោះស្រាយបញ្ហាបរិស្ថានក្នុងពេលសាងសង់ឱ្យបានឆាប់រហ័ស។ |
| គ្រាប់មិនទាន់ផ្ទុះ ឬគ្រាប់មីន (UXO) | ខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា នៅតែអាចមានសេសសល់ប្រភេទគ្រាប់មិនទាន់ផ្ទុះ ដែលអាចបង្កហានិភ័យយ៉ាងធ្ងន់ធ្ងរដល់ប្រជាកសិករ និងប្រជាជនក្នុងពេលដើរប្រមូលអនុផលព្រៃឈើនៅតាមតំបន់ព្រៃ។ ការ | ការពិគ្រោះយោបល់ជាលើកដំបូងជាមួយអាជ្ញាធរមូលដ្ឋាន គឺដើម្បីកំណត់កម្រិតនៃហានិភ័យដែលអាចកើតឡើង។ នៅទីតាំងអនុគម្រោងដែលអាចមានហានិភ័យដោយសារគ្រាប់មិនទាន់ផ្ទុះ (UXO) ត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុនដែលមានការបញ្ជាក់ត្រឹមត្រូវដើម្បីចុះធ្វើអង្កេតពីហានិភ័យនៃគ្រាប់មិនទាន់ផ្ទុះ UXO (ឧ. ការប្រើប្រាស់ឧបករណ៍រាវគ្រាប់មីន ដើម្បីកំណត់អត្តសញ្ញាណ UXO) និងការបោសសំអាត UXO តាមតម្រូវការជាក់ស្តែង។ សម្រាប់ទីតាំងដែលមានហានិភ័យទាប លិខិតបញ្ជាក់ពីប្រសិទ្ធភាពនេះ គួរតែទទួលបានពីអាជ្ញាធរស្រុក ឬខេត្ត។ ចំពោះទីតាំងដែលត្រូវបានចុះអង្កេត និងបានបោសសម្អាតគ្រាប់មិនទាន់ផ្ទុះ គួរតែត្រូវបានបញ្ជាក់ដោយកិច្ចសហការល្អពីអាជ្ញាធរជាតិគ្រប់គ្រងសកម្មភាពកម្ចាត់មីន។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| | ដីកកកាយដែលកើតឡើងអំឡុងពេលសាងសង់របស់អនុគម្រោង ក៏អាចមានសក្តានុពលក្នុងការប្រឈមនឹងគ្រាប់មិនទាន់ផ្ទុះទាំងនេះដែរ។ | |
| ការចូលទន្ទ្រានតំបន់ការពារធម្មជាតិ, ធនធានវប្បធម៌រូបវន្ត, ទីតាំងសក្ការៈគោរពបូជា ឬវត្ថុបុរាណ។ល។ | លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងសម្រាប់គាស់ជីកយកថ្ម ជីករណ្តៅយកដី និងកន្លែងចោលសំរាម ។ល។ | <u>លក្ខណៈវិនិច្ឆ័យជ្រើសរើសទីតាំងសម្រាប់ការគាស់យកថ្ម ការជីករណ្តៅយកដី និងកន្លែងចោលសំរាម៖</u><br>- *ទីតាំងដែលស្ថិតនៅហួសពីសិទ្ធិឆ្លងកាត់/កំណត់ព្រំប្រទល់នៃតំបន់មាត់ទន្លេ យ៉ាងហោចណាស់ ៥ (ប្រាំ) ម៉ែត្រពីមាត់ទន្លេដែលមានយឿនទប់ទឹក។ យ៉ាងហោចណាស់ ១០០ (មួយរយ) ម៉ែត្រពីច្រាំងទន្លេធំដែលគ្មានយឿនទប់ទឹក; យ៉ាងហោចណាស់ ៥០ (ហាសិប) ម៉ែត្រពីច្រាំងទន្លេសម្រាប់ដៃទន្លេដែលគ្មានយឿនទប់ទឹកនៅខាងក្រៅតំបន់តាំងទីលំនៅ។*<br>- ម្យ៉ាងទៀត ប្រគល់កិច្ចសន្យាសម្រាប់ការគាស់យកថ្ម ការជីករណ្តៅយកដី និងកន្លែងចោលសំរាម ទៅឱ្យភាគីទីបីដែលមានសមត្ថកិច្ច និងមានការបញ្ជាក់ទទួលស្គាល់។ |
| ការបញ្ចេញដីល្បាប់ ឬទឹកហូរច្រោះ បណ្តាលឱ្យមានការជន់លិចប្រភពទឹក។ ការបញ្ចេញទឹកកង្វក់ពីការប្រើប្រាស់ប្រចាំថ្ងៃនៅតាមជំរុំសំណង់ និងសកម្មភាពសាងសង់ដែលបំពុលដល់ | គ្រប់ទីតាំងទាំងអស់ដែលមានការជីកលើកដី /ការឈូសឆាយដី<br><br>គ្រប់ជំរុំសំណង់ និងទីការដ្ឋានទាំងអស់ | - ជំរុំកម្មករ កន្លែងស្តុកសម្ភារៈ / កន្លែងលាងសម្អាតសម្រាប់ប្រេងឥន្ធនៈ គ្រឿងចក្រ និងយានជំនិះ ដែលមានទីតាំង > ៥០០ ម៉ែត្រពីកន្លែងប្រភពទឹក។<br>- ត្រូវត្រួតពិនិត្យការងារឱ្យបានគ្រប់ជ្រុងជ្រោយ, ដោយត្រូវផ្អាកការងារជីកកកាយរហូតដល់ពេលស្ងួត។<br>- ត្រូវប្រើប្រាស់រណ្តៅចាប់ដីល្បាប់ (slit traps) ដែលមានការធានា និងដោយប្រុងប្រយ័ត្នក្នុងពេលទុកដាក់សម្ភារៈសម្រាប់ដីកកកាយ។<br>- រាល់ការជីកលើកដីដែលមានទីតាំងក្នុងរង្វង់ចម្ងាយ ៥០ ម៉ែត្រពីទន្លេ និងប្រឡាយ នឹងត្រូវធ្វើឡើងតែក្នុងរដូវប្រាំងប៉ុណ្ណោះ។<br>- ការជីកសាងសង់រណ្តៅចាប់ដីល្បាប់ ត្រូវងាកចេញពីប្រឡាយ ដោយការដាក់របាំងឃាំង ឬមានចង្អូរនៅជុំវិញគំនរសម្ភារៈ។<br>- ត្រូវផ្តល់ការផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់ និងបង្គន់អនាម័យបណ្តោះអាសន្ននៅជំរុំកម្មករ។ ត្រូវសម្អាតអនាម័យជាប្រចាំ។<br>- សាងសង់ប្រឡាយស្ទាក់ទឹក ដើម្បីទប់ស្កាត់លំហូរច្រោះពីការសាងសង់ចូលទៅក្នុងប្រភពទឹក។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| ទឹក។ | | - ត្រូវបង្វែរលំហូរទឹកច្រោះចេញពីកន្លែងការដ្ឋាន ទៅកាន់រក្សាស្រះដីល្បាប់ ឬបង្ហូរចូលតាមលូដែលមានស្រាប់។<br>- ត្រូវសាងសង់ និងដំឡើងអាងចម្រោះដីកំណកល្បាប់ជាបណ្ដោះអាសន្ន ដើម្បីកែច្នៃឡើងវិញ។<br>- ត្រូវដំឡើងឧបករណ៍ញែកប្រេង-ទឹកនឹង មុននឹងសាងសង់អាងចម្រោះដីកំណកល្បាប់សម្រាប់ធ្វើប្រព្រឹត្តកម្មទឹកកង្វក់មានជាតិប្រេង។<br>- ត្រូវរៀបចំកន្លែងបំពាក់ម៉ាស៊ីនលាងចម្រុះ ដោយមានអាងស្តុកទឹក និងរណ្ដៅចាប់ដីល្បាប់។<br>- ត្រូវកំណត់យកទីតាំងស្តុក ឬសម្អាតសម្រាប់ប្រេងឥន្ធនៈ គ្រឿងចក្រ និងយានជំនិះ > ៥០០ ម៉ែត្រពីប្រភពទឹក។<br>- កន្លែងផ្ទុកឥន្ធនៈ ប្រេង និងសម្ភារៈគ្រោះថ្នាក់ផ្សេងទៀត នឹងស្ថិតនៅក្នុងតំបន់ដែលមានសុវត្ថិភាពលើផ្ទៃដែលមិនជ្រាបទឹក ហើយមានច្រាំងទប់ជុំវិញ និងការបោសសម្អាតជាប្រចាំ។<br>- បង្គន់អនាម័យចល័ត ឬបង្គន់ដែលសាងសង់ដែលមានអាងស្តុកទឹកស្អុយគ្រប់គ្រាន់ ដែលត្រូវផ្តល់ឱ្យកម្មករសំណង់ប្រើប្រាស់នៅនឹងកន្លែង ហើយត្រូវបញ្ចេញចោល (ឬបូមចេញ) ក្នុងលក្ខណៈសមស្របទៅក្នុងប្រព័ន្ធលូដែឡមានស្រាប់នៅខាងក្រៅទីតាំង ឬប្រព័ន្ធលូសាធារណៈ។ |
| ការបំភាយធូលីខ្យល់ និងសារធាតុបំពុលបរិយាកាសផ្សេងៗ | គ្រប់គ្រឿងបរិក្ខារទាំងអស់, ដោយយកចិត្តទុកដាក់ជាពិសេសចំពោះទីតាំងនៅជិតលំនៅឋាន សាលារៀន មន្ទីរពេទ្យ ឬការិយាល័យ | - តម្រូវឱ្យអ្នកម៉ៅការរ៉ាប់រងលើសម្ភារៈ ជាមួយនឹងក្រណាត់តង់មិនជ្រាបទឹក ឬសម្ភារៈសមស្របផ្សេងទៀតក្នុងពេលកំពុងដឹកឆ្លងកាត់ ដើម្បីជៀសវាងការកំពប់លេចធ្លាយ។<br>- ត្រូវសាចទឹកបន្សើមដីក្នុងស្ថានភាពស្ងួត និងមានធូលីច្រើន ជាពិសេសនៅតាមផ្លូវនៅជិតលំនៅឋាន និងផ្លូវក្រវ៉ាត់ក្រុង។<br>- ត្រូវកំណត់ល្បឿនបើកបរសម្រាប់យានយន្តសំណង់គ្រប់ប្រភេទ។<br>- ត្រូវអនុវត្តការថែទាំជាប្រចាំលើឧបករណ៍សំណង់ និងយានជំនិះ ដើម្បីគ្រប់គ្រងការបំភាយខ្យល់ក្នុងអំឡុងពេលប្រតិបត្តិការយានយន្ត។<br>- ទីតាំងរណ្តៅជីកយកដី និងកន្លែងចោលសំរាមត្រូវមានចម្ងាយយ៉ាងតិច ៣០០ ម៉ែត្រពីតំបន់លំនៅឋាន ដើម្បីកាត់បន្ថយការហុយធូលីពីកន្លែងទាំងនេះ។<br>- ត្រូវបានអនុវត្តតាមវិធានការទប់ស្កាត់ធូលីខ្យល់ ប្រកបដោយប្រសិទ្ធភាព។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| | | - ត្រូវផ្តល់ឱ្យកម្មករនូវឧបករណ៍ការពារខ្លួន (PPE)<br>- មជ្ឈដ្ឋានងាយរងឥទ្ធិពល ដូចជា សាលារៀន មន្ទីរពេទ្យ ឬលំនៅឋាន ត្រូវតែសាចទឹកបន្សើមជាប្រចាំនៅតាមការដ្ឋានសំណង់ ដើម្បីកុំឱ្យហុយធូលី និងបើកចំហបង្អួច ឬទ្វារសម្រាប់ឱ្យខ្យល់ចេញចូលនៅពេលជួសជុល និងកែលម្អសមណង់អគារ។ |
| សំឡេងរំខានះ ប៉ះពាល់ដល់សុខភាព កម្មករ និងសុខភាព សហគមន៍ | គ្រប់ការដ្ឋានសំណង់ទាំងអស់ ជាពិសេសការប្រើប្រាស់ ឧបករណ៍សំណង់ដែលមាន សំឡេងរំខាន | - ត្រូវដាក់កម្រិតលើសកម្មភាពសាងសង់ ជាពិសេសប្រតិបត្តិការឧបករណ៍ដែលបង្កើតសំឡេងរំខាននៅពេលយប់។<br>- ត្រូវរៀបចំដាក់ទីតាំងឧបករណ៍ទាំងឡាយណាដែលបង្កើតកម្រិតសំឡេងរំខានខ្ពស់ ដូចជាម៉ាស៊ីនភ្លើងជាដើម ឱ្យនៅឆ្ងាយពីមជ្ឈដ្ឋានដែលទទួលឥទ្ធិពល។<br>- ត្រូវដំឡើងរបាំងជញ្ជាំងបណ្តោះអាសន្ននៅជុំវិញការដ្ឋានសំណង់ ជាពិសេសនៅជិតសាលារៀន មន្ទីរពេទ្យ និងលំនៅឋាន។<br>- ត្រូវដំឡើងឧបករណ៍ទប់សំឡេងរំខាន ដើម្បីទប់សំឡេងរំខានទាំងនោះ។<br>- តម្រូវឱ្យអ្នកបើកបរកាត់បន្ថយការចុចស៊ីផ្លេ និងបើកបរដោយគោរពតាមល្បឿនកំណត់។<br>- ផ្តល់ព័ត៌មានដល់សហគមន៍តាមកាលវិភាគនៃសកម្មភាពសាងសង់ តាមរយៈផ្ទាំងប៉ាណូ/ផ្លាកសញ្ញាផ្សេងៗ។ |
| ការគាស់កកាយសារពើរុក្ខជាតិ/ការហូរច្រោះដី | គ្រប់ការដ្ឋានសំណង់ទាំងអស់, នៅលើដីព្រៃ ឬដីមានរុក្ខជាតិដុះនៅ | - ការកាប់ដើមឈើ នឹងធ្វើឡើងតាមការរចនាដែលបានព្រមព្រៀង និងដោយមានការយល់ព្រមពីអាជ្ញាធរពាក់ព័ន្ធតែប៉ុណ្ណោះ។ ជៀសវាងការកាប់ដើមឈើប្រសិនបើអាចចៀសបាន និងកាត់បន្ថយការខូចខាតដល់សារពើរុក្ខជាតិដែលដុះតាមធម្មជាតិ។<br>- ត្រូវអនុវត្តការរៀបចំទេសភាព និងដាំដើមឈើ ឬសារពើរុក្ខជាតិនានានៅតាមទីតាំងដែលបានស្នើឡើង។<br>- ផែនការគ្រប់គ្រងការហូរច្រោះដី គឺត្រូវរៀបចំដោយអ្នកម៉ៅការ និងត្រូវមានការយល់ព្រមពីអាជ្ញាធរដែលមានការទទួលខុសត្រូវមុនពេលចាប់ផ្តើមការសាងសង់។<br>- ផ្លូវថ្នល់ និងផ្លូវលំទៅហេដ្ឋារចនាសម្ព័ន្ធនានា ត្រូវមានទំហំធំទូលាយគ្រប់គ្រាន់សម្រាប់ចតយានជំនិះ ឬស្តុកសម្ភារៈសំណង់។<br>- កម្លាំងពលកម្មដោយដៃ នឹងត្រូវប្រើប្រាស់ជាប្រយោជន៍នៅតាមទីតាំងជីជម្រាល ដែលមានការប្រើប្រាស់ឧបករណ៍ធុនធ្ងន់ និងអាចបណ្តាលឱ្យខូចខាតដែលមិនចាំបាច់។ ជម្រាលដែលនៅលាតត្រដាង នឹងត្រូវរៀបចំកែលម្អ និងដាំដុះគម្របព្រៃ និងស្មៅ ដើម្បីកាត់បន្ថយការហូរច្រោះ។<br>- ត្រូវរក្សាស្ថេរភាពនៃគម្របទីជម្រាល ដោយអនុវត្តវិធានការការពារការហូរច្រោះ។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
| --- | --- | --- |
| | | - ការសាងសង់នៅតំបន់ដែលមានទឹកជន់លិច និងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ គួរតែកំណត់ជាកំហិតចាំដល់រដូវប្រាំង។<br>- ត្រូវគ្រប់គ្រងការហូរច្រោះដីល្បាប់ និងត្រូវគ្របគំនរពំនូកដី។<br>- ត្រូវកំណត់យកទីតាំងស្តុកដីបណ្តោះអាសន្ននៅតំបន់ណាដែលលំហូរទឹកច្រោះមិនអាចបង្កឱ្យមានការហូរច្រោះដីល្បាប់ចូលក្នុងប្រភពទឹក។<br>- ត្រូវបង្កើតវិធានការការពារចំពោះសកម្មភាពការងារនៅលើច្រាំងទន្លេ ការកាត់ឬឈូសគម្របជម្រាល គំនរសម្ភារៈ និងកន្លែងផ្សេងទៀតដែលប្រឈមនឹងការហូរច្រោះដីនៅពេលមានភ្លៀងធ្លាក់ខ្លាំង។<br>- ត្រូវស្តារឡើងវិញចំពោះរណ្តៅជីកយកដី កន្លែងចោលសំរាម និងទីតាំងការដ្ឋាន ដើម្បីការពារ និងកាត់បន្ថយការហូរច្រោះ។<br>- រក្សាលំនឹងទីតាំងដែលបានជីកលើកដី ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការងារជីកលើកដីបានបញ្ចប់នៅនឹងកន្លែងការដ្ឋាន។<br>- ត្រូវធ្វើការត្រួតពិនិត្យទីតាំងការដ្ឋានជាប្រចាំ និងតាមដានការហូរច្រោះដី ការបំពុល។ល។<br>- ដើមឈើដែលមានដើមកំណើតក្នុងតំបន់ ត្រូវបានប៉ះប៉ូវឡើងវិញ ហើយផ្លាស់ទៅដាក់ចាំដុះនៅទីតាំងក្បែរនោះ។ |
| ការគាស់កកាយសារពើរុក្ខជាតិ/ការហូរច្រោះដី | គ្រប់ការដ្ឋានសំណង់ទាំងអស់, នៅលើដីព្រៃ ឬដីមានរុក្ខជាតិដុះនៅ | - ការកាប់ដើមឈើ នឹងធ្វើឡើងតាមការរចនាដែលបានព្រមព្រៀង និងដោយមានការយល់ព្រមពីអាជ្ញាធរពាក់ព័ន្ធតែប៉ុណ្ណោះ។ ជៀសវាងការកាប់ដើមឈើប្រសិនបើអាចចៀសបាន និងកាត់បន្ថយការខូចខាតដល់សារពើរុក្ខជាតិដែលដុះតាមធម្មជាតិ។<br>- ត្រូវអនុវត្តការរៀបចំទេសភាព និងដាំដើមឈើ ឬសារពើរុក្ខជាតិនានានៅតាមទីតាំងដែលបានស្នើឡើង។<br>- ផែនការគ្រប់គ្រងការហូរច្រោះដី គឺត្រូវរៀបចំដោយអ្នកម៉ៅការ និងត្រូវមានការយល់ព្រមពីអាជ្ញាធរដែលមានការទទួលខុសត្រូវមុនពេលចាប់ផ្តើមការសាងសង់។<br>- ផ្លូវថ្នល់ និងផ្លូវលំទៅហេដ្ឋារចនាសម្ព័ន្ធនានា ត្រូវមានទំហំធំទូលាយគ្រប់គ្រាន់សម្រាប់ចតយានជំនិះ ឬស្តុកសម្ភារៈសំណង់។<br>- កម្លាំងពលកម្មដោយដៃ នឹងត្រូវប្រើប្រាស់ជាប្រយោជន៍នៅតាមទីតាំងដីជម្រាល ដែលមានការប្រើប្រាស់ឧបករណ៍ធុនធ្ងន់ និងអាចបណ្តាលឱ្យខូចខាតដែលមិនចាំបាច់។ ជម្រាលដែលនៅលាតត្រដាង នឹងត្រូវរៀបចំកែលម្អ និងដាំដុះគម្របព្រៃ និងស្មៅ ដើម្បីកាត់បន្ថយការហូរច្រោះ។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| | | - ត្រូវរក្សាស្ថេរភាពនៃគម្របទីជម្រាល ដោយអនុវត្តវិធានការការពារការហូរច្រោះ។<br>- ការសាងសង់នៅតំបន់ដែលមានទឹកជន់លិច និងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ គួរតែកំណត់ជាកំហិតចាំដល់រដូវប្រាំង។<br>- ត្រូវគ្រប់គ្រងការហូរច្រោះដីល្បាប់ និងត្រូវគ្របគំនរពំនូកដី។<br>- ត្រូវកំណត់យកទីតាំងស្តុកដីបណ្តោះអាសន្ននៅតំបន់ណាដែលលំហូរទឹកច្រោះមិនអាចបង្កឱ្យមានការហូរច្រោះដីល្បាប់ចូលក្នុងប្រភពទឹក។<br>- ត្រូវបង្កើតវិធានការការពារចំពោះសកម្មភាពការងារនៅលើច្រាំងទន្លេ ការកាត់ឬឈូសគម្របជម្រាល គំនរសម្ភារៈ និងកន្លែងផ្សេងទៀតដែលប្រឈមនឹងការហូរច្រោះដីនៅពេលមានភ្លៀងធ្លាក់ខ្លាំង។<br>- ត្រូវស្តារឡើងវិញចំពោះរណ្តៅជីកយកដី កន្លែងចោលសំរាម និងទីតាំងការដ្ឋាន ដើម្បីការពារ និងកាត់បន្ថយការហូរច្រោះ។<br>- រក្សាលំនឹងទីតាំងដែលបានជីកលើកដី ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការងារជីកលើកដីបានបញ្ចប់នៅនឹងកន្លែងការដ្ឋាន។<br>- ត្រូវធ្វើការត្រួតពិនិត្យទីតាំងការដ្ឋានជាប្រចាំ និងតាមដានការហូរច្រោះដី ការបំពុល។ល។<br>- ដើមឈើដែលមានដើមកំណើតក្នុងតំបន់ ត្រូវបានប៉ះប៉ូវឡើងវិញ ហើយផ្លាស់ទៅដាក់ចាំដុះនៅទីតាំងក្បែរនោះ។ |
| ផលប៉ះពាល់លើធនធានអេកូឡូស៊ី | ការដ្ឋានសំណង់ដែលនៅជិត និងងាយស្រួលចូលទៅដល់តំបន់ព្រៃ | - អ្នកម៉ៅការ នឹងហាមឃាត់ចំពោះសកម្មភាពដូចជា៖ ការកាប់ដើមឈើធ្វើអូសសម្រាប់ចម្អិនដាំស្ល ការបរបាញ់ ឬការជួញដូរសត្វព្រៃ។ |
| ផលប៉ះពាល់នៃចំនួនកម្មករបណ្តោះអាសន្ន | គ្រប់ការដ្ឋានសំណង់ទាំងអស់ | - ត្រូវចូលរួមជាមួយអ្នកម៉ៅការក្នុងស្រុក តាមលទ្ធភាពដែលធ្វើទៅបាន ដើម្បីអនុវត្តការសាងសង់ឱ្យបានល្អប្រសើរ។<br>- ត្រូវពិគ្រោះយោបល់ជាមួយប្រជាជនក្នុងតំបន់ដើម្បីអាចទទួលយកបានសម្រាប់ការដាក់ទីតាំងការដ្ឋាន។ ប្រសិនបើត្រូវសាងសង់ជំរុំសំណង់ ចាំបាច់ត្រូវទាមទារឱ្យមានការដំឡើងបង្គន់អនាម័យសមរម្យ ដូចជាបង្គន់រណ្តៅ និងកន្លែងបង្ហូរទឹកកង្វក់ជាដើម។<br>- ត្រូវរៀបចំឱ្យមានកន្លែងប្រមូលទុកដាក់សំណល់រឹង។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| | | - ត្រូវពន្យល់ដោយខ្លីដល់កម្មករ និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនមូលដ្ឋានអំពីគ្រោះថ្នាក់នៃជំងឺឆ្លង។ |
| កំទេចកំទីសំណង់ និងការកំពប់ខ្វាយ, ការបំពុលដី | គ្រប់ការដ្ឋានសំណង់ទាំងអស់ | - សម្ភារៈដែលជីកកកាយ ឬដីដែលកាប់គាស់លើសចំនួន នឹងត្រូវយកទៅប្រើប្រាស់សម្រាប់ចាក់លុបបំពេញជង្ហុកនៅតាមតំបន់ទាបៗដែលត្រូវបានកំណត់អត្តសញ្ញាណដោយអាជ្ញាធរភូមិ។<br>- ត្រូវផ្តល់ធុងសំរាមដែលអាចញែកប្រភេទសំរាមបាន ឬកន្លែងសម្រាប់ប្រមូលទុកដាក់សំណល់ពីការសាងសង់។<br>- ត្រូវធានាសុវត្ថិភាព និងគ្រប់គ្រងការការប្រមូលទុកដាក់សម្ភារៈគ្រោះថ្នាក់ទាំងអស់ រួមទាំងប្រេងឥន្ទនៈជាដើម។<br>- ត្រូវប្រើប្រាស់ឡើងវិញនូវសំណល់ពីការសាងសង់ទាំងឡាយណាដែលអាចកែច្នៃបាន ដូចជាឈើ ដែក និងរន្ទា ឬលក់ទៅឱ្យក្រុមហ៊ុនប្រមូលទិញអេតចាយ។<br>- ត្រូវប្រមូលសំណល់រឹងទាំងអស់ និងបោះចោលនៅកន្លែងចោលសំរាម ដែលមានការឯកភាពពីអាជ្ញាធរស្រុក។<br>- ត្រូវកំណត់យកទីតាំងចោលសំណល់ និងទីតាំងរណ្តៅជីកយកដី យ៉ាងហោចណាស់ចម្ងាយ ៥០ ម៉ែត្រពីទីតាំងប្រភពទឹក ឬពីកន្លែងតាំងទីលំនៅ ឬពីមជ្ឈដ្ឋានងាយរងឥទ្ធិពលផ្សេងទៀត ដូចបានកំណត់នៅក្នុងឯកសារដេញថ្លៃសាងសង់។ |
| គ្រោះថ្នាក់ដោយចៃដន្យដល់កម្មករ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន | គ្រប់ការដ្ឋានសំណង់ទាំងអស់ | - ត្រូវបែងចែកទំនួលខុសត្រូវលើការការពារសុវត្ថិភាពនៅទីតាំងការដ្ឋានដល់អ្នកគ្រប់គ្រងការដ្ឋាន ដែលនឹងអាចធានាបានចំពោះការអនុវត្តវិធានការសុវត្ថិភាពសមស្រប ដូចជាការប្រើប្រាស់សម្លៀកបំពាក់ និងឧបករណ៍សុវត្ថិភាព និងការដាក់សញ្ញាព្រមានអំពីគ្រោះថ្នាក់នៅតាមការដ្ឋាន។<br>- ត្រូវអនុវត្តការថែទាំបោសសម្អាតការដ្ឋានសំណង់ឱ្យបានល្អ ដើម្បីធានាសុវត្ថិភាពកម្មករ។<br>- ត្រូវកំណត់យកទីតាំងសម្រាប់ការញែក និងការប្រមូលរក្សាទុកសំណល់ទាំងអស់។<br>- ត្រូវផ្តល់ឧបករណ៍ពន្លត់អគ្គីភ័យដែលសមស្រប និងទុកដាក់ឧបករណ៍ពន្លត់អគ្គីភ័យនៅត្រង់កន្លែងដែលងាយឃើញច្បាស់ និងអាចយកមកប្រើប្រាស់បានពេលមានអគ្គីភ័យកើតឡើង។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| ការរំខាននៃចរាចរណ៍ទៅមក ឬការកើនឡើងនៃបរិមាណចរាចរណ៍ | គ្រប់ការដ្ឋានសំណង់ទាំងអស់ដែលស្ថិតនៅក្នុងក្រុង ឬនៅជាប់ក្រុង | - អ្នកម៉ៅការ គួររៀបចំផែនការប្រតិបត្តិការសាងសង់ដោយមានការប្រឹក្សាជាមួយអ្នករស់នៅក្នុងតំបន់នោះ និងអ្នកប្រកបរបរអាជីវកម្មនៅទីនោះ។ អាជ្ញាធរមូលដ្ឋានអាចជួយរៀបចំកន្លែងលក់ដូរបណ្ដោះអាសន្ន និងផ្លូវចរាចរណ៍ទៅមកដែលអាចជំនួសបានក្នុងអំឡុងពេលសាងសង់។<br>- ត្រូវរៀបចំផែនការគ្រប់គ្រងការធ្វើចរាចរណ៍ ដោយសហការរួមគ្នាជាមួយមន្ត្រីនគរបាលចរាចរណ៍ក្នុងមូលដ្ឋាន មុនពេលចាប់ផ្ដើមការសាងសង់ណាមួយ។ ផែនការនេះត្រូវរួមបញ្ចូលបទប្បញ្ញត្តិសម្រាប់ការបង្វែរទិចរាចរណ៍ ឬកំណត់ពេលវេលាធ្វើចរាចរណ៍សម្រាប់ការងារសាងសង់ ដើម្បីចៀសវាងការកកស្ទះនៅម៉ោងចរាចរណ៍ពេលព្រឹក និងពេលល្ងាច ដោយការសម្រួលចរាចរណ៍នៅផ្លូវបំបែកដើម្បីធានាសុវត្ថិភាពសាធារណៈ តាមរយៈការដាក់ស្លាកសញ្ញាចរាចរណ៍ឱ្យឃើញច្បាស់ ការត្រួតពិនិត្យ និងការរៀបចំផែនការ។<br>- ក្នុងករណីមានការបិទគន្លងផ្លូវណាមួយ ត្រូវដាក់កម្លាំងកម្មករឱ្យជួយសម្រួលចរាចរណ៍ដោយផ្ទាល់។<br>- ត្រូវរៀបចំដំឡើងស្លាកសញ្ញា និងលក្ខណៈបច្ចេកទេសសុវត្ថិភាពសមស្របផ្សេងទៀត ដើម្បីបង្ហាញថាការងារសំណង់កំពុងមានដំណើរការ។<br>- ត្រូវកំណត់ល្បឿនបើកបរ និងការចរាចរណ៍ចេញចូលទីតាំងការដ្ឋាន ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ដែលអាចកើតឡើង។ |
| ការរំខានដល់ផ្នែកសង្គម, ការរំខានជាបណ្ដោះអាសន្នលើផ្លូវសហគមន៍ ផ្លូវលំ និងផ្លូវធ្វើដំណើរចេញចូលផ្សេងទៀត | គ្រប់ការដ្ឋានសំណង់ទាំងអស់ដែលនៅជិតសហគមន៍មូលដ្ឋាន | - ត្រូវទុកផ្លូវថ្មើរជើង ដើម្បីបញ្ចៀសការខូចខាតដល់ទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ ហើយត្រូវទុកផ្លូវចេញចូលបណ្ដោះអាសន្នដោយក្រាលជាបន្ទះឈើ ឬសម្ភារៈស្រដៀងគ្នា។ ត្រូវយកចិត្តទុកដាក់ជាពិសេស ចំពោះការធានាសុវត្ថិភាពនៅតាមដងផ្លូវ និងផ្លូវលំដែលប្រើដោយអ្នកថ្មើរជើងទាំងអស់។<br>- ត្រូវរៀបចំដំឡើងរបាំង និងស្លាកសញ្ញាព្រមានពីគ្រោះថ្នាក់នៅលើកំណាត់ផ្លូវនានា ហើយប្រសិនបើចាំបាច់ គួរតែដាក់ពង្រាយកម្លាំងជំនួយដើម្បីសម្រួលចរាចរណ៍ ដោយមានមនុស្សកាន់ទង់ជាសញ្ញានៅតាមទីតាំងដែលរងផលប៉ះពាល់។ ត្រូវរៀបចំដំឡើងផ្ទាំងព័ត៌មាននៅតាមដងផ្លូវដែលអាចផ្ដល់ព័ត៌មានអំពីការបិទផ្លូវបណ្ដោះអាសន្ន កាលវិភាគការងារសាងសង់ និងផែនការផ្លាស់ប្ដូរទិសដៅចរាចរណ៍ ជាដើម។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
|---|---|---|
| | | - ត្រូវដំឡើងផ្លាកសញ្ញានៅកន្លែងសាងសង់ ដើម្បីជូនដំណឹងដល់ប្រជាជនអំពីគម្រោង យន្តការបណ្តឹងសាទុក្ខ គ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុ (ឧ. យានជំនិះបើកបរឆ្លងកាត់ទៅមក វត្ថុគ្រោះថ្នាក់ និងការជីកកកាយ និងបញ្ហាសុវត្ថិភាពដទៃទៀត។)<br>- ត្រូវតម្រូវឱ្យអ្នកម៉ៅការ ធ្វើការជួសជុលស្តារឡើងវិញជាបន្ទាន់ចំពោះតំបន់ដែលបានជីកកកាយ និងចំពោះផ្លូវថ្នល់ និងផ្លូវលំដែលរងការខូចខាត។<br>- ត្រូវហ៊ុមរបងព័ទ្ធជុំវិញទីតាំងការដ្ឋាន ដើម្បីឱ្យការប្រើប្រាស់ផ្លូវអាចបន្តចេញចូលជាធម្មតាបានដោយគ្មានឧបសគ្គរារាំង។<br>- ត្រូវដំឡើងរបាំងការពារសុវត្ថិភាពនៅជុំវិញកន្លែងដែលត្រូវជីកកកាយទាំងអស់។<br>- ត្រូវប្រាដកថាទីតាំងទាំងអស់ ពិតជាមានសុវត្ថិភាព និងត្រូវមានរបងជញ្ជាំងហ៊ុមព័ទ្ធឱ្យបានសមរម្យមិនបន្ទឱ្យមានការចេញចូលផ្តេសផ្តាស។<br>- ត្រូវចាក់សោរបងទាំងអស់ ហើយត្រូវប្រាកដថាទីតាំងការដ្ឋាននេះមានសុវត្ថិភាព និងហាមចេញចូលដោយគ្មានការអនុញ្ញាត។ |
| សុខភាព និងសុវត្ថិភាពសហគមន៍ | គ្រប់ការដ្ឋានសំណង់ទាំងអស់ | - មុនពេលការងារណាមួយ ត្រូវជូនដំណឹងដល់ប្រជាពលរដ្ឋ និងអាជីវករអ្នកលក់ដូរជាមុន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ផ្ទាំងព័ត៌មាន និងការពិគ្រោះយោបល់ដោយផ្ទាល់អំពីសកម្មភាពសាងសង់ កាលបរិច្ឆេទ និងរយៈពេលនៃការរំខានដែលរំពឹងទុកថាអាចកើតមាន។<br>- ត្រូវធ្វើការប្រជុំជាមួយប្រជាពលរដ្ឋមុនពេលចាប់ផ្តើមការងារណាមួយ ជាពិសេសសម្រាប់សហគមន៍ក្នុងរង្វង់ ៤០ ម៉ែត្រនៃការដ្ឋាន ហើយអ្នកដែលនឹងត្រូវទទួលរងនូវកម្រិតសំឡេងរំខានខ្លាំង ឬធូលីហុយ។<br>- កត់ត្រារាល់មតិកែលម្អសហគមន៍ និងស្វែងរកដំណោះស្រាយដែលបានពិភាក្សា និងយល់ព្រម។<br>- ផ្អែកលើមតិកែលម្អពីការពិគ្រោះយោបល់ជាមួយសហគមន៍៖ (១) អ្នកម៉ៅការត្រូវធ្វើបច្ចុប្បន្នភាពផែនការលើទីតាំងតាមតម្រូវការ ដើម្បីបញ្ចូលដំណោះស្រាយ រួមទាំងការកែសម្រួលកាលវិភាគការងារ ម៉ោងធ្វើការប្រចាំថ្ងៃ វិធីសាស្ត្រសាងសង់ និង/ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
| --- | --- | --- |
| | | ឬវិធីសាស្រ្តកាត់បន្ថយ។ (២) កែសម្រួលកាលវិភាគត្រួតពិនិត្យរបស់ CSC និងលក្ខណៈវិនិច្ឆ័យត្រួតពិនិត្យតាមតម្រូវការ ដើម្បីឆ្លុះបញ្ចាំងពីផែនការគ្រប់គ្រងទីតាំងការដ្ឋានដែលបានធ្វើបច្ចុប្បន្នភាព។ |
| ការរំខានដល់ធនធានរូបវន្ត និងវប្បធម៌ | គ្រប់ហេដ្ឋារចនាសម្ព័ន្ធទាំងអស់ | ប្រសិនបើប្រទះឃើញវត្ថុបុរាណវប្បធម៌ណាមួយដោយអ្នកម៉ៅការ រួមទាំងទីបញ្ចុះសព និង/ឬផ្នូរបុគ្គលក្នុងអំឡុងពេលជីកកកាយ ឬសាងសង់៖<br>- ក្នុងករណីប្រទះឃើញកេរតំណែលបុរាណដោយចៃដន្យ អ្នកម៉ៅការត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពការដ្ឋាន និងត្រូវការពារទីតាំងនោះឱ្យបានល្អ។<br>- កំណត់ព្រំនៃទីតាំងបុរាណដែលបានរកឃើញ។<br>- ធានាសុវត្ថិភាពលើទីតាំងនោះ ដើម្បីការពារការខូចខាត ឬការបាត់បង់វត្ថុដែលអាចដកចេញបាន (ឧ. ក្នុងករណីវត្ថុបុរាណដែលមិនអាចដកចេញបាន ឬនៅមានវត្ថុដែលសេសសល់ គួររៀបចំយាមការពារនៅពេលយប់)។<br>- ជូនដំណឹងជាបន្ទាន់ទៅវិស្វករត្រួតពិនិត្យការដ្ឋាន និងអ្នកជំនាញបរិស្ថាន និងជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច។<br>- អនុវត្តតាមការណែនាំពីអាជ្ញាធរដែលមានទំនួលខុសត្រូវទាក់ទងនឹងការផ្លាស់ប្តូរគំនូសប្លង់នៃការសាងសង់ និងបន្តការងារសាងសង់ឡើងវិញបាន បន្ទាប់ពីមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។<br>- អ្នកម៉ៅការ នឹងធានាថាកម្លាំងពលកម្មត្រូវបានរាប់បញ្ចូលពីសេចក្តីសង្ខេបលើនីតិវិធីនេះក្នុងអំឡុងពេលបណ្តុះបណ្តាលស្តីពី EMP/ECC។ |
| សុខភាព និងសុវត្ថិភាពការងារ | គ្រប់ការដ្ឋានសំណង់ទាំងអស់ | - តម្រូវឱ្យអ្នកម៉ៅការអនុវត្តផែនការបរិស្ថាន សុខភាព និងសុវត្ថិភាពនៃការងារសំណង់ ស្របតាមគោលការណ៍ណែនាំ EHS របស់ធនាគារពិភពលោក (http://www.ifc.org/ehsguidelines) តាមកម្រិតស្តង់ដាអប្បបរមា។ អ្នកម៉ៅការ ត្រូវតែងតាំងមន្ត្រីបរិស្ថាន សុខភាព និងសុវត្ថិភាព ដើម្បីធានាការអនុវត្តផែនការនេះ។ ផែនការអប្បបរមា នឹងរួមមាន:<br>• ការផ្តល់គ្រឿងបរិក្ខារសង្គ្រោះបឋមដែលកម្មករនិយោជិតអាចរកបានយ៉ាងងាយស្រួល។<br>• ការផ្តល់ឧបករណ៍ការពារខ្លួន (PPEs) ដូចជា មួករឹង ស្រោមដៃ ស្បែកជើងកៅស៊ូកវែង។ល។<br>• ការស្លៀកពាក់ឧបករណ៍ការពារខ្លួន (PPEs) នៅពេលធ្វើការនៅនឹងកន្លែង ដែលជាតម្រូវការចាំបាច់សម្រាប់កម្មករ។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| ទិដ្ឋភាពបរិស្ថាន | សកម្មភាព និងទីតាំង | វិធានការកាត់បន្ថយ |
| --- | --- | --- |
| | | • ការបិទផ្សាយស្លាកសញ្ញាសុវត្ថិភាព/សញ្ញាដាស់តឿន នៅក្នុងតំបន់ការដ្ឋាន។<br>• ការរៀបចំដំឡើងភ្លើងបំភ្លឺឱ្យបានគ្រប់គ្រាន់នៅពេលយប់។<br>• ត្រូវប្រាកដថាអ្នកបញ្ជាយានយន្ត និងប្រតិបត្តិករឧបករណ៍ផ្សេងៗ ត្រូវមានអាជ្ញាប័ណ្ណ និងឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ។<br>• ផ្តល់ឱ្យបុគ្គលិកនូវការបណ្តុះបណ្តាលស្តីពីការការពារជំងឺកូវីដ-១៩, ជំងឺឆ្លង និងជំងឺអេដស៍ ជាដើម។<br>- អ្នកម៉ៅការ នឹងតម្រូវឱ្យផ្តល់អាទិភាពការងារដល់ការជួលកម្មករសំណង់ដែលមានសមត្ថភាពនៅក្នុងភូមិនានា និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជៀសវាងជម្លោះការងារ ប្រសិនបើកម្មករចំណាកស្រុកនឹងត្រូវនាំយកមកធ្វើការនៅកន្លែងនោះ។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# ឧបសម្ព័ន្ធ D. ក្រមបរិស្ថាននៃការអនុវត្តសម្រាប់ប្រតិបត្តិការផ្សារក្រមួន

| ប្រធានបទ | បញ្ហាបរិស្ថាន សុខភាព និងសុវត្ថិភាព (EHS) | វិធានការកាត់បន្ថយ |
|---|---|---|
| ការបំពុលទឹក | បរិមាណដ៏ច្រើននៃសំណល់រឹងត្រូវបានបង្កើតក្នុងផ្សារ ដែលអាចត្រូវបានបោះចោលជាធម្មតាទៅក្នុងលូ ឬប្រឡាយទឹកនៅក្បែរនោះ ដែលបង្កឱ្យមានការស្ទះលូ និងដក់ទឹក។ | ការលើកកម្ពស់ការយល់ដឹងដល់អាជ្ញាធរឃុំ និងអ្នកគ្រប់គ្រងផ្សារទាក់ទងនឹងការប្រមូលទុកដាក់ និងគ្រប់គ្រងសំណល់រឹង (ឧ. វិធានការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ)។ |
| ការកើតឡើងនៃជំងឺឆ្លងដោយសារទឹក | ទឹកភ្លៀងព្យុះ និងការបង្ហូរទឹកសំណល់កង្វក់អាចបណ្តាលឱ្យមានទឹកដក់ និងបង្កជាជម្រកដល់ពពួកសត្វល្អិតដែលជាភ្នាក់ងារចម្លងរោគ អាចពងកូនពាសពេញតំបន់ផ្សារ។ | នៅផ្សារ គឺមានការចាក់កម្រាលបេតុង ប្រក់ដំបូលនៅលើទីតាំងលក់ដូរ និងការកែលម្អប្រព័ន្ធលូ អាចធ្វើឱ្យផ្សារកាន់តែងាយស្រួលក្នុងការរក្សាអនាម័យ និងគ្មានទឹកដក់ដែលអាចឱ្យសត្វល្អិតពងកូនបានទៀតនោះទេ។<br><br>សម្រាប់កន្លែងសត្តឃាត និងកន្លែងកែច្នៃសាច់ គឺមានការរៀបចំប្រព័ន្ធលូប្រកបដោយប្រសិទ្ធភាព ការឈូសបង្ហាប់ដីធ្វើចំណត និងការបង្ហូរទឹកកង្វក់ និងការរៀបចំទេសភាពសម្រាប់បរិវេណផ្សារទាំងមូលដើម្បីការពារទឹកដក់។ |
| ការរេចរឹលនៃប្រភពទឹក | នៅផ្សារ គឺមានការផលិតទឹកកង្វក់ដែលមានកំហាប់ខ្ពស់នៃ BOD | អាចកាត់បន្ថយការបង្កើតទឹកកង្វក់ តាមរយៈវិធានការសន្សំសំចៃទឹក។ ការអនុវត្តតាមវិធីប្រតិបត្តិការ និងការថែទាំកន្លែងប្រព្រឹត្តកម្មទឹកកង្វក់។ ផ្តល់ជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពក្នុងប្រតិបត្តិការ និងថែទាំ (O&M)។ |
| ការរំខានផ្នែកសង្គម | បញ្ហាចរាចរណ៍តែងកើតឡើងជាញឹកញាប់នៅតាមតំបន់ផ្សារក្នុងក្រុង ដោយសារយានយន្តច្រើន | មានផ្តល់ជាកំនូសប្លង់ទីតាំងល្អប្រសើរជាមុន រួមទាំងកន្លែងលើកដាក់ឥវ៉ាន់ចេញចូលដែលនៅឆ្ងាយពីផ្លូវថ្នល់ និងមានកន្លែងសម្រាប់ចតយានយន្តផងដែរ។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| | | |
|---|---|---|
| | ធ្វើចរាចរណ៍ទៅមក ដឹកជញ្ជូន និងបង្កការកកស្ទះ ជាពិសេស នៅពេលចូលចតនៅជិតផ្សារ។ | |
| សំណល់រឹង | សំណល់រឹង មានច្រើនកកកុញ នៅក្នុងទីផ្សារក្នុងអំឡុងពេល ម៉ោងលក់ដូរ ហើយប្រសិនបើទុក ចោលនៅកន្លែងនោះ គឺមើលទៅ គ្មានអនាម័យ និងអាចមានសត្វ នាំគ្នាខាំហែករប៉ាត់រប៉ាយគ្មានស ណ្ដាប់ធ្នាប់។ | នៅផ្សារ មានផ្តល់ជាកន្លែងទុកដាក់សំណល់រឹងជាបណ្តោះអាសន្នដែលអ្នកលក់ដូរអាចប្រមូលយកមកទុកដាក់បាន ហើយងាយស្រួលប្រមូលដឹកជញ្ជូនទៅកាន់កន្លែងចាក់សំរាមសមរម្យ។ ត្រូវញែកប្រភេទសំណល់ដែលអាចកែច្នៃបាន ឬអាចប្រើឡើងវិញបាន។ ត្រូវញែកសំណល់សរីរាង្គសម្រាប់កែច្នៃជាចំណីសត្វ និងជីកំប៉ុស។ |
| សុខភាព និងសុវត្ថិភាពការងារ ឬមុខរបរ | អ្នកលក់ដូរ អាចនឹងប្រឈមមុខគ្រោះថ្នាក់រាងកាយ គីមីសាស្ត្រ និងជីវសាស្ត្រ | ការអនុវត្តឧស្សាហកម្មល្អ ត្រូវបានរៀបរាប់លម្អិតនៅក្នុងគោលការណ៍ណែនាំរបស់ IFC EHS សម្រាប់ដំណើរការកែច្នៃអាហារ និងភេសជ្ជៈ៖ https://www.ifc.org/wps/wcm/connect/topics_ext_content/ifc_external_corporate_site/sustainability-at-ifc/policies-standards/ehs-guidelines<br>ការអនុវត្តតាមការណែនាំជាក់លាក់អំពីជំងឺកូវីដ-១៩ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ D គួរតែគោរពតាមយ៉ាងម៉ឺងម៉ាត់បន្ថែមទៀត។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

# ឧបសម្ព័ន្ធ E. ការគ្រប់គ្រងហានិភ័យនៃជំងឺកូវីដ-១៩ (COVID-19)

| សកម្មភាព | វិធានការកាត់បន្ថយ |
|---|---|
| ការកំណត់យកទីតាំងជំរុំសំណង់ និងការគ្រប់គ្រង | - ការកំណត់យកទីតាំងជំរុំ និងការិយាល័យធ្វើការ៖<br>• មិនស្ថិតនៅក្នុងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ ការរអិលបាក់ដី ឬគ្រោះមហន្តរាយធម្មជាតិផ្សេងទៀត<br>• មិនស្ថិតនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយធូលីពីការសំណង់ សំឡេងរំខាន ទឹកស្អុយ ឬការបំពុលផ្សេងៗ<br>• មិនស្ថិតនៅក្នុងតំបន់លំនៅឋាន<br>- កំណត់ស្តង់ដាអប្បបរមាសម្រាប់កន្លែងស្នាក់នៅ៖<br>• គ្រែដាច់ដោយឡែកសម្រាប់កម្មករ<br>• គ្រែត្រូវបានរៀបចំមិនឱ្យលើសពីពីរជួរ<br>• ការស្នាក់នៅដោយឡែកពីគ្នារវាងបុរស និងស្ត្រី ឬសម្រាប់ការស្នាក់នៅជាលក្ខណៈក្រុមគ្រួសារ<br>• កន្លែងត្រូវមានពន្លឺគ្រប់គ្រាន់<br>• កន្លែងត្រូវមានខ្យល់ចេញចូលគ្រប់គ្រាន់ ដើម្បីធានាឱ្យមានចលនាខ្យល់គ្រប់គ្រាន់<br>• ការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយសុវត្ថិភាព<br>• មានគ្រឿងបរិក្ខារអនាម័យគ្រប់គ្រាន់<br>• មានប្រព័ន្ធបង្ហូរទឹកគ្រប់គ្រាន់<br>• មានគ្រឿងសង្ហារិមគ្រប់គ្រាន់សម្រាប់កម្មករនិយោជិតម្នាក់ៗ ដើម្បីធានាដល់ការប្រើប្រាស់របស់របរផ្ទាល់ខ្លួន ដូចជាទូមានសោរជាដើម<br>• កន្លែងបរិភោគអាហារទូទៅ អាហារដ្ឋាន ត្រូវមានទីតាំងនៅឆ្ងាយពីកន្លែងស្នាក់នៅ<br>• មានទីតាំង និងគ្រឿងបរិក្ខារសមរម្យសម្រាប់បោកគក់ហាលសម្លៀកបំពាក់<br>• មានកន្លែងសម្រាប់ដោតរន្ធសាកទូរសព្ទ និងឧបករណ៍ផ្សេងទៀត<br>• កន្លែងសម្រាក និងកន្លែងកម្សាន្ត និងកន្លែងថែទាំសុខភាព ដែលមិនមាននៅក្នុងសហគមន៍ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| សកម្មភាព | វិធានការកាត់បន្ថយ |
| --- | --- |
| | - កំណត់ទំហំស្នាក់នៅអប្បបរមា៖<br>• វិមាត្រខាងក្នុងលើសពី ១៩៨ សង់ទីម៉ែត្រ គុណនឹង ៨០ សង់ទីម៉ែត្រ<br>• បន្ទប់មានចន្លោះទំនេរគ្រប់គ្រាន់ជាង ២០៣ សង់ទីម៉ែត្រ<br>• គ្រែដេកនៅយ៉ាងហោចណាស់ ២ ម៉ែត្រពីគ្នា<br>- បំពាក់គ្រឿងបរិក្ខារអនាម័យ៖<br>• មានបង្គន់មួយ ទូទឹកកកមួយ / ធុងទឹកមួយ (បង្គន់មួយ ប្រើបានសម្រាប់មនុស្ស ៦ នាក់)<br>• ទីតាំងងាយស្រួលក្នុងការស្នាក់នៅ<br>• មានផ្តល់សាប៊ូសម្រាប់ប្រើប្រាស់<br>• មានគ្រឿងបរិក្ខារប្រើប្រាស់ដាច់ដោយឡែកសម្រាប់បុរស និងស្ត្រី<br>• មានកង្ហារខ្យល់<br>• មានទឹកត្រជាក់<br>• កន្លែងស្អាត និងមានអនាម័យ<br>• មានអាងស្តុកទឹកស្អុយ និងកន្លែងប្រព្រឹត្តិកម្មទឹកកង្វក់ ឬបង្គន់អនាម័យដែលមានទីតាំងយ៉ាងហោចណាស់ ២០០ ម៉ែត្រពីទីតាំងប្រភពទឹក និងនៅក្នុងតំបន់ដែលមានទម្រង់ដីសមស្រប និងខ្ពស់ជាងកម្រិតទឹកក្រោមដី<br>- រៀបចំមានផាសុខភាព និងសុវត្ថិភាពក្នុងកន្លែងស្នាក់នៅរបស់កម្មករ៖<br>• មានទីតាំងដាច់ដោយឡែកសម្រាប់កម្មករឈឺសម្រាក និងដើម្បីការពារការចម្លងជំងឺ<br>• មានបំពាក់ឧបករណ៍ចាប់ផ្សែងនៅតាមកន្លែងដេក<br>• សុវត្ថិភាពអគ្គីភ័យនៅគ្រប់កន្លែងស្នាក់នៅដូចជា បំពង់ពន្លត់អគ្គីភ័យ ការប្រកាសអាសន្នអគ្គីភ័យ ក្រណាត់ភួយគ្របភ្លើង<br>• ការបណ្តុះបណ្តាលកម្មករក្នុងការការពារបង្ការ និងរបៀបនៃការពន្លត់អគ្គីភ័យ<br>• មានស្លាកសញ្ញាបង្ហាញច្រកចេញពេលមានអគ្គីភ័យ មធ្យោបាយរំដោះខ្លួនគ្រប់គ្រាន់ និងអាចឃើញស្លាកសញ្ញាអាសន្នយ៉ាងច្បាស់ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| សកម្មភាព | វិធានការកាត់បន្ថយ |
|---|---|
| | • ការដាក់ភ្លើងសុវត្ថិភាពនៅក្នុងជំរុំសំណង់ និងមានភ្លើងបំភ្លឺចាប់បន្ទប់ដេក ទៅដល់ទីតាំងបន្ទប់អនាម័យ<br>• ខ្សែចរន្តអគ្គិសនីមានសុវត្ថិភាព ដោយលើកឱ្យបានខ្ពស់ផុតពីដី និងមិនស្ថិតនៅក្នុងតំបន់ដែលមានទឹកជន់លិច<br>- អនុវត្តការត្រួតពិនិត្យជាប្រចាំ៖<br>• ការត្រួតពិនិត្យលើការលាងសម្អាតអនាម័យ ២ ដងប្រចាំសប្តាហ៍ ត្រួតពិនិត្យស្ថានភាពនៃការជួសជុលអគារ កន្លែងស្នាក់នៅ និង ឧបករណ៍អគ្គីភ័យ<br>• កត់ត្រាលទ្ធផលនៃការត្រួតពិនិត្យ និងរក្សាទុកសម្រាប់ពិនិត្យកែសម្រួលនៅពេលក្រោយ |
| លក្ខខណ្ឌការងារនៅក្នុងការដ្ឋានសំណង់ | • បង្កើតក្រុមរួមគ្នាដើម្បីធ្វើផែនការ និងរៀបចំដំណើរការការងារ និងការផ្លាស់ប្តូរវេនការងារ<br>• បង្កើត ឬកោះប្រជុំគណៈកម្មការសុវត្ថិភាពការងារ និងសុខភាព រួមគ្នាជាមួយសមាជិកតំណាងឱ្យនិយោជក និងកម្មករនិយោជិត<br>• បណ្តុះបណ្តាលសមាជិកក្រុមអំពីគោលការណ៍ជាមូលដ្ឋានសម្រាប់ការបង្កើត និងអនុវត្តវិធានការបង្ការការពារ និងត្រួតពិនិត្យសុវត្ថិភាព ការងារ និងសុខភាព<br>• បង្កើត និងផ្សព្វផ្សាយពីផែនការការងារប្រកបដោយសុវត្ថិភាពដើម្បីបង្ការការពារជំងឺកូវីដ-១៩<br>• ផែនការនេះ គួរតែអនុលោមពេញលេញជាមួយនឹងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់រដ្ឋាភិបាលស្តីពីការការពារ និងការគ្រប់គ្រងជំងឺកូវីដ-១៩ ឬស្របតាមគោលការណ៍ណែនាំការអនុវត្តល្អជាអន្តរជាតិ ដែលអាចធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយ<br>• ការវាយតម្លៃហានិភ័យ ដើម្បីសម្រេចថាតើពេលណាត្រូវធ្វើការ អ្នកណាខ្លះត្រូវធ្វើការ និងរបៀបធ្វើការ<br>• អនុវត្តការវាយតម្លៃហានិភ័យ ដើម្បីកំណត់វិធានការបង្ការ និងត្រួតពិនិត្យ<br>• ត្រូវប្រាកដថាមានវិធានការបង្ការគ្រប់គ្រាន់ មុនពេលចាប់ផ្តើមការងារសាងសង់<br>• យល់ព្រមអនុវត្តវិធានការវិស្វកម្ម រៀបចំ និងរដ្ឋបាល<br>• ជៀសវាងការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ និងត្រូវរក្សាគម្លាតពីគ្នា ដូចដែលបានកំណត់ដោយវិធានការគម្លាតសុវត្ថិភាពយ៉ាងហោចណាស់ ២ ម៉ែត្រ ឬស្របតាមការអនុវត្តល្អជាអន្តរជាតិ<br>• បញ្ចេញខ្យល់ពីក្នុងកន្លែងធ្វើការដែលបិទជិត រួមទាំងជំរុំការងារ និងកន្លែងប្រើប្រាស់រួម |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| សកម្មភាព | វិធានការកាត់បន្ថយ |
| --- | --- |
| | • ជៀសវាងការប្រមូលផ្តុំកម្មករ ដោយកំណត់គម្លាតនៅតាមទីតាំងរួម ដូចជាកន្លែងទទួលទានអាហារ ជំរុំការងារ និងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់ ដើម្បីរក្សាគម្លាតជាអប្បបរមា ២ ម៉ែត្រ និងរៀបចំផ្លូវដើរចេញចូលតែមួយ។ ការរក្សាគម្លាតនេះ រាប់បញ្ចូលទាំងនៅកន្លែងដេកដែលត្រូវតែមានគម្លាតចន្លោះយ៉ាងហោចណាស់ ២ ម៉ែត្ររវាងគ្រែដេកនីមួយៗ<br>• រៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងព័ត៌មានអំពីជំងឺកូវីដ-១៩ និងវិធានការចាំបាច់សម្រាប់ការការពារ និងគ្រប់គ្រងជំងឺ<br>• ការដ្ឋានសំណង់ត្រូវញែកដាច់ពីគ្នាតាមទំហំដែលមាន ឬអនុវត្តវិធីសាស្ត្រផ្សេងទៀត ដើម្បីរក្សាគម្លាតបុគ្គលិកឱ្យនៅដាច់ដោយឡែកពីគ្នាគ្រប់ពេលវេលា<br>• កំណត់ពេលសម្រាក និងអាហារថ្ងៃត្រង់ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅប្រមូលផ្តុំគ្នាច្រើន<br>• សម្អាត និងរម្ងាប់មេរោគឱ្យបានទៀងទាត់<br>• បង្កើនការលាងសម្អាតឱ្យបានញឹកញាប់ និងការរម្ងាប់មេរោគ ជាពិសេសតំបន់ដែលមានមនុស្សប្រមូលផ្តុំច្រើន និងតំបន់ទូទៅ រួមទាំងជំរុំការងារ<br>• ត្រូវបាញ់អាល់កុល ឬថ្នាំរម្ងាប់មេរោគយ៉ាងហោចណាស់ពីរដងក្នុងមួយថ្ងៃ នៅតាមដៃទ្វារ រនាំង ជណ្តើរ កុងតាក់ភ្លើង តេឡេបញ្ជា កម្រាលហូបបាយ និងឧបករណ៍ប្រើប្រាស់រួម ទុយោ បង្គន់ និងកន្លែងផ្ទាល់ខ្លួន<br>• ចៀសវាងការចែករំលែករបស់របរប្រើប្រាស់រួមគ្នាដូចជា ពែង កែវ ចាន សម្ភារៈផ្សេងៗ<br>• លើកកម្ពស់ការថែរក្សាអនាម័យផ្ទាល់ខ្លួន<br>• ផ្តល់ឱ្យកម្មករនូវលក្ខខណ្ឌ និងមធ្យោបាយចាំបាច់សម្រាប់ការលាងសម្អាតដៃញឹកញាប់ (សោយសាប៊ូ ទឹក ឬដៃលអាល់កុល) ជាមួយនឹងរបៀបលាងសម្អាតដៃដែលបានបិទបង្ហាញនៅតាមច្រកចេញចូល បន្ទប់ទឹក តំបន់សហគមន៍ ការិយាល័យ និងកន្លែងផ្សេងទៀតដែលមានផ្ទៃប៉ះពាល់ញឹកញាប់<br>• ណែនាំដល់កម្មករឱ្យជៀសវាងការប៉ះពាល់រាងកាយ ឬចាប់ដៃគ្នា និងជៀសវាងការយកម្រាមដៃទៅប៉ះភ្នែក ច្រមុះ និងមាត់<br>• ណែនាំឱ្យកម្មករខ្ទប់មាត់ និងច្រមុះដោយក្រដាស ឬកន្សែងដៃ នៅពេលក្អក ឬកណ្តាស់ ឬខ្ទប់មាត់ និងច្រមុះដោយប្រើកែងដៃ<br>• បោះចោលក្រដាស់ប្រើរួចក្នុងធុងសំរាម ហើយលាងដៃឱ្យបានស្អាត |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| សកម្មភាព | វិធានការកាត់បន្ថយ |
|---|---|
| | • ផ្តល់ឧបករណ៍ការពារខ្លួន (PPE) និងជូនដំណឹងដល់កម្មករអំពីការប្រើប្រាស់ឧបករណ៍នេះឱ្យបានត្រឹមត្រូវ<br>• កំណត់អត្តសញ្ញាណឧបករណ៍ការពារខ្លួន (PPE) ដែលសមស្របទាក់ទងនឹងភារកិច្ច និងហានិភ័យសុខភាព និងសុវត្ថិភាព ផ្អែកតាមលទ្ធផលនៃការវាយតម្លៃហានិភ័យ និងកម្រិតនៃហានិភ័យ ហើយផ្តល់ឱ្យកម្មករដោយមិនគិតថ្លៃ និងក្នុងចំនួនគ្រប់គ្រាន់ រួមជាមួយនឹងការណែនាំ របៀបប្រើប្រាស់ ការបណ្តុះបណ្តាល និងការត្រួតពិនិត្យ<br>• ផ្តល់របាំងមុខដែលមិនមែនវេជ្ជសាស្ត្រ (ដូចជាម៉ាស់ធ្វើពីក្រណាត់ ដែលផ្តល់ដោយអ្នកម៉ៅការដល់កម្មករនិយោជិតទាំងអស់ និងអ្នកត្រួតពិនិត្យការដ្ឋាន) ដើម្បីកាត់បន្ថយការឆ្លងមេរោគ ប៉ុន្តែការពាក់ម៉ាស់ការពារនេះ មិនត្រូវចាត់ទុកជាការជំនួសការលាងសម្អាតដៃនោះទេ<br>• ការតាមដានសុខភាព និងការធានារ៉ាប់រង<br>• មុននឹងចូលក្នុងទីតាំងការដ្ឋាន បុគ្គលិក កម្មករ ឬភ្ញៀវពីក្រៅត្រូវតែបញ្ជាក់ថាពួកគេមិនមានរោគសញ្ញាអ្វីមួយ ដូចគ្រុនផ្តាសាយ ជាដើម<br>• តាមដានស្ថានភាពសុខភាពរបស់កម្មករ បង្កើតពិធីសារសម្រាប់ករណីសង្ស័យ និងករណីបានឆ្លងជំងឺកូវីដ-១៩។ ពិធីសារនេះនឹងបញ្ជាក់ថា៖<br>១). កម្មករដែលមានរោគសញ្ញា ឬករណីបានឆ្លងជំងឺ ត្រូវតែដាក់ឱ្យនៅដាច់ដោយឡែកក្នុងជំរុំសំណង់ ឬស្នាក់នៅផ្ទះរយៈពេល ៧ ថ្ងៃបន្ទាប់ពីមានរោគសញ្ញា<br>• ប្រសិនបើរោគសញ្ញានៅតែបន្តកើតមានក្រោយរយៈពេល ៧ ថ្ងៃ អ្នកជំងឺត្រូវដាក់ឱ្យនៅដាច់ដោយឡែករហូតដល់បាត់រោគសញ្ញា<br>• អ្នកដែលបានពាក់ព័ន្ធផ្ទាល់ជាមួយអ្នកដែលបានឆ្លងជំងឺកូវីដ-១៩ ត្រូវដាក់ឱ្យនៅដាច់ដោយឡែករយៈពេល ១៤ ថ្ងៃ<br>២). កម្មករនិយោជិតទាំងអស់ដែលតម្រូវឱ្យធ្វើចត្តាឡីស័ក ត្រូវតែផ្តល់អាហារ ទឹក ជំនួយផ្នែកវេជ្ជសាស្ត្រ និងអនាម័យគ្រប់គ្រាន់<br>• កំណត់អត្តសញ្ញាណកម្មករដែលបានពាក់ព័ន្ធផ្ទាល់ជាមួយអ្នកឆ្លងជំងឺកូវីដ-១៩ និងអនុវត្តតាមគោលការណ៍ណែនាំវេជ្ជសាស្ត្រ<br>• ជូនដំណឹងទៅកាន់អាជ្ញាធរពាក់ព័ន្ធអំពីករណីរកឃើញនៃការឆ្លងជំងឺកូវីដ-១៩<br>• កម្មករទាំងអស់ គួរតែត្រូវបានផ្តល់ការធានារ៉ាប់រងសុខភាព ដែលមានរួមបញ្ចូលកញ្ចប់ព្យាបាលជំងឺកូវីដ-១៩<br>• ពិចារណាពីគ្រោះថ្នាក់ផ្សេងៗ រួមទាំងផ្នែកផ្លូវចិត្តផងដែរ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| សកម្មភាព | វិធានការកាត់បន្ថយ |
|---|---|
| | • លើកកម្ពស់បរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសុខភាព ដោយគ្មានអំពើហិង្សា និងការយាយី<br>• លើកទឹកចិត្តដល់ការលើកកម្ពស់សុខភាព និងសុខុមាលភាពនៅកន្លែងធ្វើការ តាមរយៈការសម្រាកឱ្យបានគ្រប់គ្រាន់ តុល្យភាពនៃសកម្មភាពរាងកាយ និងផ្លូវចិត្ត និងតុល្យភាពជីវិតការងារឱ្យបានគ្រប់គ្រាន់<br>• អនុវត្តវិធានការបង្ការ និងត្រួតពិនិត្យសម្រាប់ការប្រើប្រាស់ និងការរក្សាទុកសារធាតុគីមី ជាពិសេសថ្នាំដែលប្រើសម្រាប់ម្លាប់មេរោគក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩<br>• អ្នកម៉ៅការ នឹងត្រូវបានស្នើឱ្យបង្កើត និងពិនិត្យឡើងវិញលើផែនការត្រៀមលក្ខណៈបង្ការ និងសង្គ្រោះបន្ទាន់ និងរៀបចំវិធានការសំខាន់ៗដើម្បីការពារ និងគ្រប់គ្រងជំងឺរាតត្បាត ហើយពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពផែនការរបស់ខ្លួនឱ្យបានទៀងទាត់។ ផែនការនេះ គួរតែរួមបញ្ចូលៈ<br>  ○ ត្រូវកំណត់ការទទួលខុសត្រូវច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រង អ្នកត្រួតពិនិត្យ និងបុគ្គលិក<br>  ○ ត្រូវប្រាកដថានិយោជិតម្នាក់ៗត្រូវយល់ដឹងដោយខ្លួនឯងអំពីរោគសញ្ញានៃជំងឺកូវីដ-១៩<br>  ○ ត្រូវផ្តល់ការណែនាំអំពីវិធីសាស្រ្តគ្រប់គ្រង និងបង្ការជំងឺដល់កម្មករនិយោជិតទាំងអស់ ជាពិសេសហានិភ័យនៃការប៉ះពាល់<br>  ○ ត្រូវផ្តល់ការណែនាំសម្រាប់និយោជកទាក់ទងនឹងការអនុវត្តសុវត្ថិភាពសម្រាប់ "បុគ្គលិកផ្នែកហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ" ដែលអាចមានជាក់ពាក់ព័ន្ធផ្ទាល់ជាមួយបុគ្គលដែលមានករណីសង្ស័យ ឬបញ្ជាក់ថាមានជំងឺកូវីដ-១៩<br>  ○ ត្រូវបង្កើតវិធានការការពារនៅគ្រប់កន្លែងការងារទាំងអស់<br>  ○ ត្រូវផ្តល់ឧបករណ៍ការពារខ្លួន (PPE) និងការត្រួតពិនិត្យការអនុវត្តការងារជាប្រចាំ<br>  ○ អនុវត្តការថែរក្សាអនាម័យជាប្រចាំ ដែលរួមមានការលាងសម្អាត និងការម្លាប់មេរោគឱ្យបានញឹកញាប់ទៅលើសម្ភារៈប្រើប្រាស់ផ្សេងៗនិងវត្ថុធាតុផ្សេងៗទៀតជុំវិញបរិយាកាសការងារ<br>  ○ ស្ថានភាពប៉ះពាល់ដែលជាប់ពាក់ព័ន្ធនៅកន្លែងការងារៈ<br>    ▪ នយោជិតដែលចេញរោគសញ្ញាជំងឺកូវីដ-១៩<br>    ▪ និយោជិតដែលធ្វើតេស្តឃើញវិជ្ជមានជំងឺកូវីដ-១៩ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.

| សកម្មភាព | វិធានការកាត់បន្ថយ |
|---|---|
| | ▪ និយោជិតជាប់ពាក់ព័ន្ធផ្ទាល់ជាមួយបុគ្គលដែលធ្វើតេស្តឃើញវិជ្ជមានជំងឺកូវីដ-១៩<br>○ ការកត់ត្រា និងការរាយការណ៍<br>• តាមដានជាប្រចាំនូវវិធានការបង្ការ និងការត្រួតពិនិត្យ ដើម្បីកំណត់ឱ្យច្បាស់ថាពួកគេមានការយល់ដឹងគ្រប់គ្រាន់អំពីវិធីជៀសវាង ឬកាត់បន្ថយហានិភ័យ និងអនុវត្តសកម្មភាពកែតម្រូវសម្រាប់ការកែលម្អជាបន្តបន្ទាប់<br>• បង្កើត និងរក្សាការកត់ត្រាទាក់ទងនឹងរបួស ជំងឺ និងឧប្បត្តិហេតុក្នុងពេលបំពេញការងារ ការប៉ះពាល់ផ្ទាល់រវាងកម្មករ ការត្រួតពិនិត្យបរិយាកាសការងារ និងសុខភាពរបស់កម្មករ។ |



INTERNAL. This information is accessible to ADB Management and staff. It may be shared outside ADB with appropriate permission.